សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប
ASIA EURO UNIVERSITY

លេខ:..០១៩/១៦....បផក/សអអ

# បទបញ្ជាផ្ទៃក្នុង

## សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្ររង ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងបរិញ្ញាបត្រ នៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

## សាកលវិទ្យាធិការ

- បានឃើញអនុក្រឹត្យលេខ០៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៥ ស្តីពីការទទួលស្គាល់ការប្រែក្លាយពីវិទ្យាស្ថាន អាស៊ី អឺរ៉ុប ទៅជាសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប
- បានឃើញប្រកាសលេខ១៤៣៥ អយក.ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌនិងលក្ខណវិនិច្ឆ័យលម្អិតសម្រាប់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សា
- បានឃើញសេចក្តីសម្រេចលេខ២៨៥/១៥ សអអ/សសរ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប
- បានឃើញសេចក្តីសម្រេចលេខ២៦៦/១៤ សអអ/សសរ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍ណែនាំសម្រាប់ស្រាវជ្រាវ និងសរសេរសារណាថ្នាក់ឧត្តមសិក្សាកម្រិតបរិញ្ញាបត្រ នៃមហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- បានឃើញសេចក្តីសម្រេចលេខ២៦៧/១៤ សអអ/សសរ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍ណែនាំសម្រាប់ស្រាវជ្រាវនិងសរសេរសារណាថ្នាក់ឧត្តមសិក្សាកម្រិតបរិញ្ញាបត្រ នៃមហាវិទ្យាល័យសង្គមសាស្ត្រ និងសេដ្ឋកិច្ច និងមហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍ ព្រមទាំងមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ
- បានឃើញសេចក្តីសម្រេចផ្ទៃក្នុងលេខ ១៧៧/១៥ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥ ស្តីពីគោលការណ៍ណែនាំនិងនីតិវិធីសម្រាប់វាយតម្លៃ និងដាក់ពិន្ទុលើរបាយការណ៍បញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រ នៃមហាវិទ្យាល័យសង្គមសាស្ត្រ និងសេដ្ឋកិច្ច មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្មនិងទេសចរណ៍ និងមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ។
- បានឃើញសេចក្តីសម្រេចលេខ ១៦៧/០៩ ស.អ.អ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីបទបញ្ជាផ្ទៃក្នុងសម្រាប់និស្សិតសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប
- យោងគោលការណ៍លេខ ៣១១/១៥ សអអ/គល ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ស្តីពី ការវាយតម្លៃលទ្ធផលប្រឡង និងកាលបរិច្ឆេទនៃការប្រឡងសងរបស់និស្សិត ដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្ររងនៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប



អគ្គការ អាស៊ី អឺរ៉ុប
#832,Kampuchea Krom Blvd, Toek Laak I,Tuol Kork,
Phnom Penh, Cambodia.
HP: 017 27 06 86 / 077 72 56 68

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប (ទីស្នាក់ការកណ្តាល)
#826, Kampuchea Krom Blvd,Toek Laak I
Tuol Kok, Phnom Penh, Cambodia. Postal Code:12156
HP: 015 72 00 72 / 012 48 17 38
Phone/Fax: 023 998 124 / E-mail: info@aeu.edu.kh/ website: www.AEU.edu.kh

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប (អគារមាស)
Hotel - Restaurant - Cisco Tangberg
Court Room - Conference Hall - Lab - Gym...
#60, St. 146⊥257,Toek Laak II, Tuol Kork
Phnom Penh Cambodia.

- យោងគោលការណ៍លេខ ៣១០/១៥ សអអ/គក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការបង់ថ្លៃសិក្សា និងថ្លៃសេវាផ្សេងៗរបស់និស្សិតថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់ក្រោយបរិញ្ញាបត្រ
- យោងគោលការណ៍លេខ ៣១១/១៥ សអអ/គក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការវាយតម្លៃលទ្ធផលប្រឡង និងកាលបរិច្ឆេទនៃការប្រឡងសង របស់និស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្ររង នៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប
- គោលការណ៍លេខ ២២១/១០ សអអ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីគោលការណ៍ផ្ទេរ និងទទួលស្គាល់ក្រេឌីត នៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប
- យោងស្មារតីអង្គប្រជុំថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់និស្សិត និងគ្រូបង្រៀនថ្នាក់បរិញ្ញាបត្ររង ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងថ្នាក់បរិញ្ញាបត្រ
- យោងស្មារតីអង្គប្រជុំថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦ ស្តីពីវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្ររង ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងបរិញ្ញាបត្រ នៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប
- យោងតាមការចាំបាច់សម្រាប់ការបណ្តុះបណ្តាលថ្នាក់ឧត្តមសិក្សា។

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

### ប្រការ១.- គោលបំណង

បទបញ្ជាផ្ទៃក្នុងនេះ មានគោលបំណងជានាឱ្យមានការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងថ្នាក់បរិញ្ញាបត្រ នៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ប្រកបដោយគុណភាព និងប្រសិទ្ធិភាព ព្រមទាំងអ្នកសិក្សាស្រាវជ្រាវទទួលបានចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាប្រកបដោយសីលធម៌ ។

### ប្រការ២.- គោលដៅ

បទបញ្ជាផ្ទៃក្នុងនេះមានគោលដៅ ៖

- កំណត់អំពីវិធាន លក្ខខណ្ឌ និងរបៀបរបបសិក្សាសម្រាប់ថ្នាក់បរិញ្ញាបត្ររង ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងថ្នាក់បរិញ្ញាបត្រ
- ជួយឱ្យនិស្សិតបានរៀបចំលក្ខណៈសម្បត្តិរបស់ខ្លួនបានត្រឹមត្រូវ ដើម្បីទទួលបានជោគជ័យ ក្នុងការសិក្សារហូតដល់ទីបញ្ចប់។

### ប្រការ៣.- បញ្ញត្តិ

គ្មានឃ្លា ឬប្រយោគណានៅក្នុងបទបញ្ជាផ្ទៃក្នុងនេះ យកទៅបកស្រាយខុសពីការពិតឡើយ។ ចំពោះចំណុចណាមួយដែលមានការយល់មិនច្បាស់លាស់ ត្រូវសួរបញ្ជាក់ដោយផ្ទាល់ជាមួយគណៈគ្រប់គ្រង ឬបុគ្គលិកជាន់ខ្ពស់ នៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប។

ការប្រព្រឹត្តខុសពីបទបញ្ជាផ្ទៃក្នុងនេះ នឹងត្រូវទទួលពិន័យដូចមានចែងក្នុងប្រការ៤៦។

# ជំពូកទី២

## គោលការណ៍ និងលក្ខខណ្ឌ សម្រាប់ការជ្រើសរើសនិស្សិតឱ្យចូលរៀន

### ប្រការ៤.- គោលការណ៍នៃការជ្រើសរើសនិស្សិត

ការជ្រើសរើសនិស្សិតឱ្យចូលរៀននៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប អាចមានពីររូបភាព ៖

- **រូបភាពទី១ ៖** ធ្វើការជ្រើសរើសចំពោះបេក្ខជន ដែលមានព្រឹត្តិបត្រពិន្ទុនៅពេលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ ការជ្រើសរើសនេះ ធ្វើឡើងដោយផ្អែកលើនិទ្ទេសនៃមុខវិជ្ជាប្រឡង និងចំណាត់ថ្នាក់របស់បេក្ខជន ***និង/ឬ***
- **រូបភាពទី២ ៖** ធ្វើការជ្រើសរើសដោយឆ្លងកាត់ការប្រឡងប្រជែង (ប្រឡងជ្រើសរើស)។

### ប្រការ៥.- លក្ខខណ្ឌ និងសំណុំលិខិតសម្រាប់ការជ្រើសរើស

#### ៥.១- ថ្នាក់បរិញ្ញាបត្ររង

និស្សិតដែលមានបំណងចង់សិក្សាថ្នាក់បរិញ្ញាបត្ររង ត្រូវមានសំណុំលិខិតដូចខាងក្រោម ៖

- ពាក្យសុំចូលរៀននៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ចំនួន ០១ច្បាប់
- ប្រវត្តិរូបដែលមានបិទរូបថត (៤ គុណ ៦ ស.ម) ចំនួន ០១ច្បាប់
- ព្រឹត្តិបត្រពិន្ទុបញ្ចប់មធ្យមសិក្សាទុតិយភូមិ ឬវិញ្ញាបនបត្របញ្ជាក់ប្រឡងធ្លាក់មធ្យមសិក្សាទុតិយភូមិ ឬវិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬមធ្យមសិក្សាកម្រិត២ ឬវិញ្ញាបនបត្របណ្តោះអាសន្នបច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ឬសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ឬវិញ្ញាបនបត្របណ្តោះអាសន្នបញ្ជាក់បញ្ចប់ថ្នាក់បរិញ្ញាបត្ររង ឬមធ្យមសិក្សាឯកទេស ឬមធ្យមសិក្សាគរុកោសល្យ ឬសញ្ញាបត្របរិញ្ញាបត្ររង ឬសញ្ញាបត្រមធ្យមសិក្សាឯកទេស ឬសញ្ញាបត្រមធ្យមសិក្សាគរុកោសល្យ ឬសញ្ញាបត្រមានតម្លៃស្មើ (មានបញ្ជាក់បានថតចម្លងតាមច្បាប់ដើម) ចំនួន ០២ច្បាប់
- រូបថតក្នុងពេលបច្ចុប្បន្ន ទំហំ (៤ គុណ ៦ ស.ម) ចំនួន ០៣សន្លឹក
- រូបថតក្នុងពេលបច្ចុប្បន្ន ទំហំ (៣ គុណ ៤ ស.ម) ចំនួន ០៣សន្លឹក។

#### ៥.២- ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

និស្សិតដែលមានបំណងចង់សិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ត្រូវមានសំណុំលិខិតដូចខាងក្រោម ៖

- ពាក្យសុំចូលរៀននៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ចំនួន ០១ច្បាប់
- ប្រវត្តិរូបដែលមានបិទរូបថត (៤ គុណ ៦ ស.ម) ចំនួន ០១ច្បាប់
- ព្រឹត្តិបត្រពិន្ទុបញ្ចប់មធ្យមសិក្សាទុតិយភូមិ ឬវិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬមធ្យមសិក្សាកម្រិត២ ឬវិញ្ញាបនបត្របណ្តោះអាសន្នបច្ចេកទេស និងវិជ្ជាជីវកម្រិត៣ ឬសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ឬវិញ្ញាបនបត្របណ្តោះអាសន្នបញ្ជាក់បញ្ចប់ថ្នាក់បរិញ្ញាបត្ររង ឬមធ្យមសិក្សាឯកទេស ឬមធ្យមសិក្សាគរុកោសល្យ

ឬសញ្ញាបត្របរិញ្ញាបត្ររង ឬសញ្ញាបត្រមធ្យមសិក្សាឯកទេស ឬសញ្ញាបត្រមធ្យមសិក្សាគរុកោសល្យ ឬសញ្ញាបត្រមានតម្លៃស្មើ (មានបញ្ជាក់បានថតចម្លងតាមច្បាប់ដើម) ចំនួន ០២ច្បាប់

- រូបថតក្នុងពេលបច្ចុប្បន្ន ទំហំ (៤ គុណ ៦ ស.ម) ចំនួន ០៣សន្លឹក
- រូបថតក្នុងពេលបច្ចុប្បន្ន ទំហំ (៣ គុណ ៤ ស.ម) ចំនួន ០៣សន្លឹក។

**៥.៣- ថ្នាក់បរិញ្ញាបត្រ**

និស្សិតដែលមានបំណងចង់សិក្សាថ្នាក់បរិញ្ញាបត្រ ត្រូវមានសំណុំលិខិតដូចខាងក្រោម ៖

- ពាក្យសុំចូលរៀននៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ចំនួន ០១ច្បាប់
- ប្រវត្តិរូបដែលមានបិទរូបថត (៤ គុណ ៦ ស.ម) ចំនួន ០១ច្បាប់
- ព្រឹត្តិបត្រពិន្ទុបញ្ចប់មធ្យមសិក្សាទុតិយភូមិ ឬវិញ្ញាបនបត្របណ្ដោះអាសន្នមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬមធ្យមសិក្សាកម្រិត២ ឬវិញ្ញាបនបត្របណ្ដោះអាសន្នបច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ឬសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ឬវិញ្ញាបនបត្របណ្ដោះអាសន្នបញ្ជាក់បញ្ចប់ថ្នាក់បរិញ្ញាបត្ររង ឬមធ្យមសិក្សាឯកទេស ឬមធ្យមសិក្សាគរុកោសល្យ ឬសញ្ញាបត្របរិញ្ញាបត្ររង ឬសញ្ញាបត្រមធ្យមសិក្សា ឯកទេស ឬសញ្ញាបត្រមធ្យមសិក្ស គរុកោសល្យ ឬសញ្ញាបត្រមានតម្លៃស្មើ (មានបញ្ជាក់បានថតចម្លងតាមច្បាប់ដើម) ចំនួន ០២ច្បាប់
- វិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋានមាន GPA ចាប់ពី ២ ឡើង (មានបញ្ជាក់បានថតចម្លងតាមច្បាប់ដើម) ចំនួន ០២សន្លឹក
- រូបថតក្នុងពេលបច្ចុប្បន្ន ទំហំ (៤ គុណ ៦ ស.ម) ចំនួន ០៣សន្លឹក
- រូបថតក្នុងពេលបច្ចុប្បន្ន ទំហំ (៣ គុណ ៤ ស.ម) ចំនួន ០៣សន្លឹក។

## ប្រការ៦.- មុខវិជ្ជាត្រូវធ្វើការជ្រើសរើស ឬប្រឡងជ្រើសរើសចូលរៀន

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប នឹងធ្វើការប្រឡងជ្រើសរើស ឬធ្វើការជ្រើសរើសនិស្សិតឱ្យចូលសិក្សាឆ្នាំទី១ ឆមាសទី១ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ឬឆ្នាំទី១ នៃថ្នាក់បរិញ្ញាបត្រ ចំនួនពីរ (០២) លើក ក្នុងឆ្នាំសិក្សានីមួយៗ ដូចខាងក្រោម ៖

- ប្រឡងជ្រើសរើសលើកទី១ ៖ មិនហួសពីខែវិច្ឆិកា នៃចុងឆ្នាំនីមួយៗ
- ប្រឡងជ្រើសរើសលើកទី២ ៖ មិនហួសពីខែមេសា នៃដើមឆ្នាំនីមួយៗ។

មុខវិជ្ជាដែលត្រូវធ្វើការប្រឡងជ្រើសរើស ឬធ្វើការជ្រើសរើសតាមឯកទេសនីមួយៗមានដូចខាងក្រោម ៖

**៦.១- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា**

| ល.រ | ឯកទេស | មុខវិជ្ជាជ្រើសរើស ឬវិញ្ញាសាត្រូវប្រឡងជ្រើសរើស | | |
|---|---|---|---|---|
| | | ទី១ | ទី២ | ទី៣ |
| ១ | *ភាសាអង់គ្លេស* | ភាសាអង់គ្លេស | ចំណេះដឹងទូទៅ | ប្រវត្តិវិទ្យា |
| ២ | *អក្សរសាស្ត្រចិន* | ភាសាចិន | ចំណេះដឹងទូទៅ | ភាសាអង់គ្លេស |

| ល.រ | ឯកទេស | មុខវិជ្ជាជ្រើសរើស ឬវិញ្ញាសាត្រូវប្រឡងជ្រើសរើស | | |
|---|---|---|---|---|
| | | ទី១ | ទី២ | ទី៣ |
| ៣ | ភាសាចិនសម្រាប់ពាណិជ្ជកម្ម | ភាសាចិន | ចំណេះដឹងទូទៅ | ភាសាអង់គ្លេស |
| ៤ | ទំនាក់ទំនងអន្តរជាតិ (សិក្សាជាភាសាអង់គ្លេស) | ភាសាអង់គ្លេស | ចំណេះដឹងទូទៅ | ប្រវត្តិវិទ្យា |
| ៥ | ទំនាក់ទំនងអន្តរជាតិ | ប្រវត្តិវិទ្យា | ពលរដ្ឋវិទ្យា | ភាសាអង់គ្លេស |

## ៦.២- មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

| ល.រ | ឯកទេស | មុខវិជ្ជាជ្រើសរើស ឬវិញ្ញាសាត្រូវប្រឡងជ្រើសរើស | | |
|---|---|---|---|---|
| | | ទី១ | ទី២ | ទី៣ |
| ១ | វិទ្យាសាស្ត្រកុំព្យូទ័រ | គណិតវិទ្យា | រូបវិទ្យា | ភាសាអង់គ្លេស |
| ២ | បច្ចេកវិទ្យាព័ត៌មាន | គណិតវិទ្យា | រូបវិទ្យា | ភាសាអង់គ្លេស |
| ៣ | ការគ្រប់គ្រងប្រព័ន្ធព័ត៌មាន | គណិតវិទ្យា | រូបវិទ្យា | ភាសាអង់គ្លេស |

## ៦.៣- មហាវិទ្យាល័យសង្គមសាស្ត្រ និងសេដ្ឋកិច្ច

| ល.រ | ឯកទេស | មុខវិជ្ជាជ្រើសរើស ឬវិញ្ញាសាត្រូវប្រឡងជ្រើសរើស | | |
|---|---|---|---|---|
| | | ទី១ | ទី២ | ទី៣ |
| ១ | សេដ្ឋកិច្ច | គណិតវិទ្យា | ពលរដ្ឋវិទ្យា | ភាសាអង់គ្លេស |
| ២ | ធនាគារនិងហិរញ្ញវត្ថុ | គណិតវិទ្យា | ពលរដ្ឋវិទ្យា | ភាសាអង់គ្លេស |
| ៣ | ពាណិជ្ជកម្មអន្តរជាតិ | គណិតវិទ្យា | ភូមិវិទ្យា | ភាសាអង់គ្លេស |
| ៤ | អភិវឌ្ឍន៍សហគមន៍ | គណិតវិទ្យា | ភូមិវិទ្យា | ភាសាអង់គ្លេស |

## ៦.៤- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍

| ល.រ | ឯកទេស | មុខវិជ្ជាជ្រើសរើស ឬវិញ្ញាសាត្រូវប្រឡងជ្រើសរើស | | |
|---|---|---|---|---|
| | | ទី១ | ទី២ | ទី៣ |
| ១ | គ្រប់គ្រង | គណិតវិទ្យា | ពលរដ្ឋវិទ្យា | ភាសាអង់គ្លេស |
| ២ | គ្រប់គ្រងធនធានមនុស្ស | គណិតវិទ្យា | ពលរដ្ឋវិទ្យា | ភាសាអង់គ្លេស |
| ៣ | ម៉ាឃីធីង (Marketing) | គណិតវិទ្យា | ពលរដ្ឋវិទ្យា | ភាសាអង់គ្លេស |
| ៤ | គណនេយ្យ | គណិតវិទ្យា | ពលរដ្ឋវិទ្យា | ភាសាអង់គ្លេស |
| ៥ | គ្រប់គ្រងសណ្ឋាគារនិងទេសចរណ៍ | ប្រវត្តិវិទ្យា | ភូមិវិទ្យា | ភាសាអង់គ្លេស |

## ៦.៥- មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ

| ល.រ | ឯកទេស | មុខវិជ្ជាជ្រើសរើស ឬវិញ្ញាសាត្រូវប្រឡងជ្រើសរើស | | |
|---|---|---|---|---|
| | | ទី១ | ទី២ | ទី៣ |
| ១ | នីតិឯកជន | ប្រវត្តិវិទ្យា | ពលរដ្ឋវិទ្យា | ភាសាអង់គ្លេស |
| ២ | នីតិសាធារណៈ | ប្រវត្តិវិទ្យា | ពលរដ្ឋវិទ្យា | ភាសាអង់គ្លេស |
| ៣ | វិទ្យាសាស្ត្រនយោបាយ | ប្រវត្តិវិទ្យា | ពលរដ្ឋវិទ្យា | ភាសាអង់គ្លេស |
| ៤ | រដ្ឋបាលសាធារណៈ | ប្រវត្តិវិទ្យា | ពលរដ្ឋវិទ្យា | ភាសាអង់គ្លេស |

**ប្រការ៧.- ការរៀបចំយន្តការជ្រើសរើស ឬប្រឡងជ្រើសរើសចូលរៀន**

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ត្រូវសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតគណៈកម្មការជ្រើសរើស ឬប្រឡងជ្រើសរើសចូលរៀន ដើម្បីឱ្យដំណើរការជ្រើសរើសឬប្រឡងជ្រើសរើសប្រព្រឹត្តទៅដោយប្រសិទ្ធិភាព និងមានតម្លាភាព។

តួនាទីនិងភារកិច្ចគណៈកម្មការជ្រើសរើស ឬប្រឡងជ្រើសរើសផ្សេងៗទៀត ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៨.- ការប្រកាសលទ្ធផល**

គណៈកម្មការជ្រើសរើស ឬប្រឡងជ្រើសរើសចូលរៀនត្រូវរៀបចំរបាយការណ៍ និងលទ្ធផលនៃការប្រឡងដើម្បីជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យនិងសម្រេច។

## ជំពូកទី៣

## កម្មវិធីសិក្សានិងការបង្រៀន

**ប្រការ៩.- រយៈពេលសិក្សា**

- ០១ឆ្នាំសិក្សាចែកចេញជា០២ឆមាស។ ០១ឆមាសមានចំនួន១៥សប្តាហ៍ ដោយមិនគិតពីសប្តាហ៍ប្រឡង
- ថ្នាក់បរិញ្ញាបត្ររង តម្រូវឱ្យសិក្សារយៈពេល០២ឆ្នាំ ឬរយៈពេលប្រហាក់ប្រហែល
- ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានជាឆ្នាំទី១ នៃថ្នាក់បរិញ្ញាបត្រ ដែលតម្រូវឱ្យសិក្សារយៈពេល០១ឆ្នាំ
- ថ្នាក់បរិញ្ញាបត្រ តម្រូវឱ្យសិក្សារយៈពេល០៣ឆ្នាំ ឬរយៈពេលប្រហាក់ប្រហែល (ថ្នាក់បរិញ្ញាបត្រដោយរាប់បញ្ចូលថ្នាក់ឆ្នាំសិក្សាមូលដ្ឋានត្រូវសិក្សារយៈពេល០៤ឆ្នាំ ឬរយៈពេលប្រហាក់ប្រហែល)។

**ប្រការ១០.- ការកំណត់ចំនួនក្រេឌីត**

ក្រេឌីតនៅក្នុងកម្មវិធីសិក្សានៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ត្រូវបានកំណត់ដូចខាងក្រោម៖

ក/ ថ្នាក់បរិញ្ញាបត្ររង ៖ មានចំនួនសរុបយ៉ាងតិច៦០ក្រេឌីត សិក្សារយៈពេល ២ឆ្នាំ

ខ/ ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ៖ មានចំនួនសរុបយ៉ាងតិច៣០ក្រេឌីត សិក្សារយៈពេល ១ឆ្នាំ

គ/ ថ្នាក់បរិញ្ញាបត្រ ៖ មានចំនួនសរុបយ៉ាងតិច៩០ក្រេឌីត សិក្សារយៈពេល ៣ឆ្នាំ។

**ប្រការ១១.- មុខវិជ្ជាបំពេញបន្ថែម**

ចំពោះនិស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដែលមានបំណងចង់ប្តូរឯកទេសថ្មី ត្រូវបង់ថ្លៃ និងសិក្សាលើមុខវិជ្ជាដែលត្រូវបំពេញបន្ថែម ដើម្បីមានមូលដ្ឋានចាប់យកឯកទេសថ្មីដែលចង់ប្តូរនោះ ដោយមានការឯកភាពពីគណៈគ្រប់គ្រងតាមឯកទេសសាមី និងក្រសួងអប់រំ យុវជន និងកីឡា។

ចំពោះនិស្សិតថ្នាក់បរិញ្ញាបត្រ ដែលមានបំណងចង់ប្តូរឯកទេសថ្មី អាចអនុញ្ញាតបានត្រឹមតែក្នុងឆ្នាំទី២ ឆមាសទី១ ហើយត្រូវបង់ថ្លៃ និងសិក្សាលើមុខវិជ្ជាដែលត្រូវបំពេញបន្ថែម ដើម្បីមានមូលដ្ឋានចាប់យកឯកទេសថ្មីដែលចង់ប្តូរនោះ ដោយមានការឯកភាពពីគណៈគ្រប់គ្រងតាមឯកទេសសាមី និងក្រសួងអប់រំ យុវជន និងកីឡា។

ចំពោះនិស្សិត ថ្នាក់បរិញ្ញាបត្ររង ដែលមានបំណងចង់ប្តូរឯកទេសថ្មី អាចអនុញ្ញាតបានត្រឹមតែក្នុងឆ្នាំទី១ ឆមាសទី២ ហើយត្រូវបង់ថ្លៃ និងសិក្សាលើមុខវិជ្ជាដែលត្រូវបំពេញបន្ថែមដើម្បីមានមូលដ្ឋានចាប់យកឯកទេសថ្មីដែលចង់ប្តូរនោះ ដោយមានការឯកភាពពីគណៈគ្រប់គ្រងតាមឯកទេសសាមី និងក្រសួងអប់រំ យុវជន និងកីឡា។

## ប្រការ១២.- ការផ្ទេរ និងទទួលស្គាល់ក្រេឌីត

ដើម្បីការពង្រឹងគុណភាពសិក្សា និងមានគោលការណ៍ផ្ទេរការសិក្សា ព្រមទាំងទទួលស្គាល់ក្រេឌីតនិស្សិតឱ្យចូលសិក្សា និងផ្ទេរការសិក្សាមានលក្ខណៈច្បាស់លាស់ សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប បានអនុវត្តគោលការណ៍ ស្តីពីការផ្ទេរ និងទទួលស្គាល់ក្រេឌីត ដូចខាងក្រោម ៖

ក- **ប្រព័ន្ធក្រេឌីត** គឺជាយន្តការសម្រាប់ការសិក្សាមិនពេញម៉ោង ឬការបញ្ចូលគ្នានូវការសិក្សាពេញម៉ោងផង និងការសិក្សាមិនពេញម៉ោងផង។

**ការផ្ទេរក្រេឌីត** គឺជាការទទួលស្គាល់ជាផ្លូវការរបស់គ្រឹះស្ថានឧត្តមសិក្សាមួយ លើមុខវិជ្ជាទាំងឡាយដែលនិស្សិតបានបញ្ចប់ដោយជោគជ័យនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាផ្សេងទៀត។ មួយឆ្នាំសិក្សាត្រូវបានចែកចេញជាពីរឆមាស។ មួយឆមាសមានចំនួនយ៉ាងតិច ១៥សប្តាហ៍។

ខ- ការផ្ទេរក្រេឌីត ឬការសិក្សា ***ត្រូវធ្វើឡើងនៅពេលដើមឆមាសនីមួយៗនៃឆ្នាំសិក្សាតាមកាលបរិច្ឆេទជាក់ស្តែង*** ឬតាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម ៖

- **លើកទី១** ចាប់ពីថ្ងៃទី០១ ខែមីនា ដល់ថ្ងៃទី៣១ ខែកក្កដា សម្រាប់ការចូលរៀននៅឆមាសទី១ នៃឆ្នាំសិក្សា
- **លើកទី២** ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ដល់ថ្ងៃទី៣១ ខែធ្នូ សម្រាប់ការចូលរៀននៅឆមាសទី២ នៃឆ្នាំសិក្សា

គ- និស្សិតដែលធ្វើការផ្ទេរក្រេឌីត ឬផ្ទេរការសិក្សានិស្សិតត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- **សម្រាប់ថ្នាក់បរិញ្ញាបត្ររង**
  - ***បន្តចាប់ពីឆ្នាំទី១ ឆមាសទី២ ដល់ឆ្នាំទី២ ឆមាសទី១* និស្សិតត្រូវមាន ៖**
    - ពាក្យសុំផ្ទេរដោយបញ្ជាក់ពីគោលបំណង
    - ព្រឹត្តិបត្រពិន្ទុដែលបញ្ជាក់ច្បាស់លាស់នូវមុខវិជ្ជា ចំនួនក្រេឌីត ចំនួនម៉ោង និងពិន្ទុ ដែលទទួលបាន
    - លិខិតបញ្ជាក់ការសិក្សា
    - សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ ឬវិញ្ញាបនបត្របញ្ជាក់ប្រឡងធ្លាក់មធ្យមសិក្សាទុតិយភូមិ
- **សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន**
  - ***បន្តនៅឆ្នាំទី១ ឆមាសទី២* និស្សិតត្រូវមាន ៖**
    - ពាក្យសុំផ្ទេរដោយបញ្ជាក់ពីគោលបំណង
    - ព្រឹត្តិបត្រពិន្ទុដែលបញ្ជាក់ច្បាស់លាស់នូវមុខវិជ្ជា ចំនួនក្រេឌីត ចំនួនម៉ោង និងពិន្ទុ ដែលទទួលបាន
    - លិខិតបញ្ជាក់ការសិក្សា
    - សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ
- **សម្រាប់ថ្នាក់បរិញ្ញាបត្រ**
  - ***បន្តចាប់ពីឆ្នាំទី២ ឆមាសទី១ ដល់ឆ្នាំទី៣ ឆមាសទី២* និស្សិតត្រូវមាន ៖**
    - ពាក្យសុំផ្ទេរដោយបញ្ជាក់ពីគោលបំណង
    - ព្រឹត្តិបត្រពិន្ទុដែលបញ្ជាក់ច្បាស់លាស់នូវមុខវិជ្ជា ចំនួនក្រេឌីត ចំនួនម៉ោង និងពិន្ទុ ដែលទទួលបាន ឬ/និងវិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

- លិខិតបញ្ជាក់ការសិក្សា
- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ

○ *ថ្នាក់បន្តយកបរិញ្ញាបត្រ (ចប់បរិញ្ញាបត្ររង ឬមធ្យមសិក្សាឯកទេស ឬមធ្យមសិក្សាគរុកោសល្យ បន្តចូលថ្នាក់បរិញ្ញាបត្រ)* និស្សិតត្រូវមាន ៖

- ពាក្យសុំផ្ទេរដោយបញ្ជាក់ពីគោលបំណង
- ព្រឹត្តិបត្រពិន្ទុដែលបញ្ជាក់ច្បាស់លាស់នូវមុខវិជ្ជា ចំនួនក្រេឌីត ចំនួនម៉ោង និងពិន្ទុ ដែលទទួលបាន
- វិញ្ញាបនបត្របណ្ដោះអាសន្ន បញ្ជាក់បញ្ចប់ថ្នាក់បរិញ្ញាបត្ររង ឬមធ្យមសិក្សាឯកទេស ឬមធ្យមសិក្សាគរុកោសល្យ ឬសញ្ញាបត្របរិញ្ញាបត្ររង ឬសញ្ញាបត្រមធ្យមសិក្សា ឯកទេស ឬសញ្ញាបត្រមធ្យមសិក្សាគរុកោសល្យ
- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ ឬវិញ្ញាបនបត្របញ្ជាក់ ប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ

<u>សម្គាល់</u> ៖ - ក្នុងករណីក្រោយបញ្ចប់ការសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និស្សិតមានបំណងចង់ប្ដូរឯកទេស ឬមហាវិទ្យាល័យនិស្សិតត្រូវបានអនុញ្ញាត លុះត្រាតែសិក្សាបន្ថែមលើមុខវិជ្ជាដែលសាកលវិទ្យាល័យបានកំណត់ ព្រោះកម្មវិធីសិក្សាមានមុខវិជ្ជាខុសគ្នាតិច ឬច្រើនពីជំនាញមួយទៅជំនាញមួយ

- និស្សិតដែលផ្ទេរពីគ្រឹះស្ថានឧត្ដមសិក្សាផ្សេងៗ ត្រូវសិក្សាបន្ថែមលើមុខវិជ្ជាដែលសាកលវិទ្យាល័យបានកំណត់ ព្រោះកម្មវិធីសិក្សាមានមុខវិជ្ជាខុសគ្នាតិច ឬច្រើនពីគ្រឹះស្ថានឧត្ដមសិក្សាមួយទៅគ្រឹះស្ថានឧត្ដមសិក្សាមួយ។

**ឃ**- ក្រេឌីតដែលអាចទទួលស្គាល់ត្រូវបំពេញលក្ខខណ្ឌដូចតទៅ ៖

- គោរពតាមសេចក្ដីសម្រេចលេខ ០២ អយក.សសរ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០១ ស្ដីពីការផ្ទេរការសិក្សាពីគ្រឹះស្ថានឧត្ដមសិក្សាមួយ ទៅគ្រឹះស្ថានឧត្ដមសិក្សាមួយ ចំពោះនិស្សិតសិក្សាបង់ថ្លៃ និងសេចក្ដីសម្រេចលេខ ០៤/០៤ គ.ទ.ក ស.ស.រ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្ដីពីការអនុវត្តកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត និងការផ្ទេរក្រេឌីត របស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ព្រមទាំងសេចក្ដីសម្រេចលេខ ០៦អយក.សសរ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ ស្ដីពីការផ្ទេរការសិក្សារបស់និស្សិតនៅតាមគ្រឹះស្ថានឧត្ដមសិក្សា
- លក្ខខណ្ឌនៃការបណ្ដុះបណ្ដាលសមស្រប
- ជានិស្សិតដែលមិនត្រូវបានចាត់ទុកថាត្រួតថ្នាក់ដោយគ្រឹះស្ថានឧត្ដមសិក្សាណាមួយ។

## ប្រការ១៣.- ការវាយតម្លៃលទ្ធផលសិក្សា

រូបមន្តនៃការគណនាមធ្យមភាគតាមមុខវិជ្ជានីមួយៗ

| | |
|---|---|
| - វត្តមាននិងសកម្មភាពចូលរួមក្នុងពេលសិក្សា (Class Participation) | ១០% |
| - ប្រឡងពាក់កណ្ដាលឆមាស (Midterm Exam) | ២០% |
| - កិច្ចការស្រាវជ្រាវ (Assignment) | ២០% |
| - ប្រឡងបញ្ចប់មុខវិជ្ជាសិក្សា (Final Exam) | ៥០% |
| **សរុប** | **១០០%** |

<u>សម្គាល់</u> ៖ ពិន្ទុ **≥៥០%** ចាត់ទុកថា **ជាប់**, ពិន្ទុ **<៥០%** ចាត់ទុកថា **ធ្លាក់**។

## ប្រការ១៤.- ប្រព័ន្ធផ្តល់ពិន្ទុ និងនិទ្ទេស

| អត្ថន័យនិទ្ទេស Meaning | ពិន្ទុជាភាគរយ Mark Obtained % | និទ្ទេសជាអក្សរ Grade | ពិន្ទុនិទ្ទេស Grade Point |
|---|---|---|---|
| ល្អប្រសើរ Excellent | 85-100 | A | 4.00 |
| ល្អណាស់ Very Good | 80-84 | B+ | 3.50 |
| ល្អ Good | 70-79 | B | 3.00 |
| ល្អបង្គួរ Fairly Good | 65-69 | C+ | 2.50 |
| មធ្យម Fair | 50-64 | C | 2.00 |
| ធ្លាក់ Failure | 0-49 | D | 0.00 |

## ប្រការ១៥.- របៀបគណនាកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប

រូបមន្តគណនាកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (Grade Point Average-GPA) គឺ ៖ មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point-P) និង តម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ( Attempted Credit Value-C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

$$GPA = \frac{\sum (P \times C)}{\sum C}$$

## ជំពូកទី៤
## លក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការបញ្ចប់ការសិក្សា

## ប្រការ១៦.- ការរៀបចំយន្តការប្រឡងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ត្រូវសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតគណៈកម្មការប្រឡងបញ្ចប់ការសិក្សាមួយ ដើម្បីឱ្យដំណើរការប្រឡងបញ្ចប់ការសិក្សាប្រព្រឹត្តទៅដោយប្រសិទ្ធិភាព និងមានតម្លាភាព។

តួនាទី និងភារកិច្ចគណៈកម្មការប្រឡងបញ្ចប់ការសិក្សាត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

## ប្រការ១៧.- ការប្រកាសលទ្ធផលបញ្ចប់ការសិក្សា

គណៈមេប្រយោគ ត្រូវរៀបចំរបាយការណ៍ និងលទ្ធផល ដើម្បីជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យ និងសម្រេច។

## ប្រការ១៨.- របាយការណ៍ស្រាវជ្រាវ ឬសារណា និងចុះកម្មសិក្សាបង្រៀនសាកល្បង

ក/ និស្សិតថ្នាក់បរិញ្ញាបត្រទាំងអស់នៃមហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្មនិងទេសចរណ៍ និងមហាវិទ្យាល័យសង្គមសាស្ត្រនិងសេដ្ឋកិច្ច ព្រមទាំងមហាវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រនយោបាយ ត្រូវមានកាតព្វកិច្ចស្រាវជ្រាវ និងសរសេររបាយការណ៍ ឬសារណាបញ្ចប់ការសិក្សា ។

ខ/ និស្សិតថ្នាក់បរិញ្ញាបត្រទាំងអស់នៃមហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ត្រូវមានកាតព្វកិច្ចស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ការសិក្សា ។

គ/ និស្សិតទាំងអស់នៃមហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា៖

- ឯកទេសភាសាអង់គ្លេសមានកាតព្វកិច្ចចុះកម្មសិក្សាបង្រៀនសាកល្បង (Practicum) និងសរសេររបាយការណ៍បង្រៀនសាកល្បង
- ឯកទេសអក្សរសាស្ត្រចិនមានកាតព្វកិច្ចចុះកម្មសិក្សាបង្រៀនសាកល្បង (Practicum) និងសរសេររបាយការណ៍បង្រៀនសាកល្បង
- ឯកទេសភាសាចិនសម្រាប់ពាណិជ្ជកម្ម ចុះកម្មសិក្សា និងសរសេររបាយការណ៍បញ្ចប់ការសិក្សា
- ឯកទេសទំនាក់ទំនងអន្តរជាតិ ត្រូវមានកាតព្វកិច្ចស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ការសិក្សា។

ឃ/ និស្សិតថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្ររងទាំងអស់ មានកាតព្វកិច្ចធ្វើការប្រឡងបញ្ចប់ការសិក្សា (Comprehensive Exam) បន្ទាប់ពីបានបញ្ចប់មុខវិជ្ជាសិក្សាទាំងអស់នៃកម្រិតសិក្សាដោយជោគជ័យ។

## ប្រការ១៩.- ការវាយតម្លៃរបាយការណ៍ស្រាវជ្រាវ ឬសារណា

ក្រោយពីបានឯកភាពពីគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃ លើប្រធានបទរួចមក លទ្ធផលនៃការស្រាវជ្រាវត្រូវបង្កើតជាគណៈកម្មការរួម ដើម្បីគ្រប់គ្រង និងវាយតម្លៃដូចខាងក្រោម៖

ក/ ការវាយតម្លៃរបាយការណ៍ស្រាវជ្រាវ ត្រូវបានបែងចែកជា៖

| | |
|---|---|
| - ទម្រង់ និងរចនាសម្ព័ន្ធ | ៣០% |
| - ខ្លឹមសារ | ៦០% |
| - អក្ខរាវិរុទ្ធ | ១០% |
| **សរុប** | **១០០%** |

ខ/ ការវាយតម្លៃសារណាបញ្ចប់ ត្រូវបានបែងចែកជា៖

**សំណេរ (ពិន្ទុអតិបរិមា ៦០%)**

| | |
|---|---|
| - ទម្រង់ និងរចនាសម្ព័ន្ធ | ១០% |
| - ខ្លឹមសារ | ៤០% |
| - អក្ខរាវិរុទ្ធ | ១០% |

**ឧទ្ទេសនាម (ពិន្ទុអតិបរិមា ៤០%)**

- ការពន្យល់ ២០%
- ការឆ្លើយសំណួរ ១៥%
- ឥរិយាបថ អត្តចរិត ០៥%

ដោយឡែកសម្រាប់មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការវាយតម្លៃសារណាបញ្ចប់ត្រូវបានបែងចែកជា៖

**សំណេរ (ពិន្ទុអតិបរិមា ៣៥%)**

- ទម្រង់ និងរចនាសម្ព័ន្ធ ១០%
- ខ្លឹមសារ ២០%
- អក្ខរាវិរុទ្ធ ០៥%

**ឧទ្ទេសនាម (ពិន្ទុអតិបរិមា ៤០%)**

- ការពន្យល់ ២០%
- ការឆ្លើយសំណួរ ១៥%
- ឥរិយាបថ អត្តចរិត ០៥%

**កម្មវិធី និងការអនុវត្ត (ពិន្ទុអតិបរិមា ២៥%)**

- លទ្ធផល ១៥%
- រចនាបថ ០៥%
- បញ្ហា ០៥%

## ប្រការ២០.- ការប្រកាសលទ្ធផលរបាយការណ៍ និងសារណា

ការប្រកាសលទ្ធផលនៃការពិនិត្យវាយតម្លៃរបាយការណ៍គឺពិន្ទុចាប់ពី ៦០% ឡើងទៅប្រកាសថាជាប់ជាស្ថាពរ ចំណែកសារណាគឺពិន្ទុចាប់ពី ៧០% ឡើងទៅប្រកាសថាជាប់ជាស្ថាពរ។ ចំពោះលទ្ធផលដែលទទួលបានចំពោះរបាយការណ៍ក្រោម ៦០% និងសារណាក្រោម ៧០% ត្រូវបានប្រកាសថាធ្លាក់ ហើយត្រូវបានពិនិត្យវាយតម្លៃឱ្យរៀបចំឡើងវិញឬធ្លាក់ជាស្ថាពរទៅតាមគណៈកម្មការវាយតម្លៃ ព្រមទាំងត្រូវបង់ប្រាក់ពិន័យដល់គណៈកម្មការតាមគោលការណ៍ណែនាំរបស់មហាវិទ្យាល័យសាមី។

## ប្រការ២១.- ការវាយតម្លៃការបង្រៀន (Practicum)

ការវាយតម្លៃការបង្រៀន (Practicum) ត្រូវបានបែងចែកជាផ្នែកធំៗ៖

- Practical Teaching 80%
- Practicum Portfolio Preparation 05%
- Practicum Journal 05%
- Practicum Report 10%

**សរុប** **១០០**

## ប្រការ២២.- ការប្រកាសលទ្ធផលការបង្រៀន ( Practicum )

ចំពោះការវាយតម្លៃថាជាប់ជាស្ថាពរលុះត្រាតែនិស្សិតបំពេញឱ្យបានគ្រប់លក្ខខណ្ឌ និងទទួលបានពិន្ទុ ចាប់ពី ៥០% ឡើងទៅ ព្រមទាំងប្រគល់ឯកសារឱ្យបានទាន់ពេលវេលាមកការិយាល័យសាមី។ ផ្ទុយពីនេះនិស្សិតត្រូវបានប្រកាសថាធ្លាក់ ហើយត្រូវបានពិនិត្យវាយតម្លៃឱ្យរៀបចំឡើងវិញឬធ្លាក់ជាស្ថាពរទៅតាមគណៈកម្មការវាយតម្លៃ ព្រមទាំងត្រូវបង់ប្រាក់ពិន័យដល់គណៈកម្មការតាមគោលការណ៍ណែនាំរបស់មហាវិទ្យាល័យសាមី។

## ប្រការ២៣.- របាយការណ៍ សារណា និងការចុះកម្មសិក្សាបង្រៀនសាកល្បង

ចំពោះគោលការណ៍ណែនាំលម្អិតស្តីពី របាយការណ៍ សារណា និងការចុះកម្មសិក្សាបង្រៀនសាកល្បង មានចែងក្នុងបញ្ញត្តិដោយឡែក។

# ជំពូកទី៥
# ការបង់ថ្លៃសិក្សា វិន័យ សីលធម៌ និងសិទ្ធិរបស់និស្សិត

## ប្រការ២៤.- ការបង់ថ្លៃសិក្សា

ក/ មុននឹងចូលរៀននិស្សិតទាំងអស់ត្រូវបង់ថ្លៃសិក្សាជាមុន ទើបអាចអនុញ្ញាតឱ្យចូលរៀនបាន

ខ/ ការបង់ថ្លៃសិក្សារបស់និស្សិតមានបីលក្ខខណ្ឌគឺ អាចបង់ជាឆមាស ឬ បង់ជាឆ្នាំសិក្សា និងបង់ផ្តាច់

គ/ ចំពោះនិស្សិតរូបណាដែលមានការយឺតយ៉ាវក្នុងការបង់ថ្លៃសិក្សា ដូចមានចែងក្នុងចំណុច **ក/** នោះនឹងត្រូវបានទទួលនូវការផាកពិន័យ ដូចមានចែងខាងក្រោម ៖

+ សម្រាប់ការបង់ថ្លៃសិក្សាប្រចាំឆមាស
  - **<u>ករណីទី១</u>**: ក្នុងករណីបង់ប្រាក់យឺតក្រោយថ្ងៃចូលរៀន ≤ **២០ថ្ងៃ** នោះ ត្រូវទទួលការផាកពិន័យជាទឹកប្រាក់ចំនួន **$៥ (ប្រាំដុល្លារ)** បូកបន្ថែមលើចំនួនទឹកប្រាក់ ដែលត្រូវបង់ប្រចាំឆមាស។
  - **<u>ករណីទី២</u>**: ក្នុងករណីបង់ប្រាក់យឺតក្រោយថ្ងៃចូលរៀន ≤ **៣០ថ្ងៃ** នោះ ត្រូវទទួលការផាកពិន័យជាទឹកប្រាក់ចំនួន **$១០ (ដប់ដុល្លារ)** បូកបន្ថែមលើចំនួនទឹកប្រាក់ ដែលត្រូវបង់ប្រចាំឆមាស។
  - **<u>ករណីទី៣</u>**: ក្នុងករណីបង់ប្រាក់យឺតក្រោយថ្ងៃចូលរៀន ≤ **៦០ថ្ងៃ** នោះ ត្រូវទទួលការផាកពិន័យជាទឹកប្រាក់ចំនួន **$២០ (ម្ភៃដុល្លារ)** បូកបន្ថែមលើចំនួនទឹកប្រាក់ ដែលត្រូវបង់ប្រចាំឆមាស។
  - **<u>ករណីទី៤</u>**: ក្នុងករណីបង់ប្រាក់យឺតក្រោយថ្ងៃចូលរៀន≤**៩០ថ្ងៃ** នោះត្រូវទទួលការផាកពិន័យជាទឹកប្រាក់ចំនួន **$៣០ (សាមសិបដុល្លារ)** បូកបន្ថែមលើចំនួនទឹកប្រាក់ ដែលត្រូវបង់ប្រចាំឆមាស។

+ សម្រាប់ការបង់ថ្លៃសិក្សាប្រចាំឆ្នាំ
  - **<u>ករណីទី១</u>**: ក្នុងករណីបង់ប្រាក់យឺតក្រោយថ្ងៃចូលរៀន ≤ **៣០ថ្ងៃ** នោះ ត្រូវទទួលការផាកពិន័យជាទឹកប្រាក់ចំនួន **$២០ (ម្ភៃដុល្លារ)** បូកបន្ថែមលើចំនួនទឹកប្រាក់ ដែលត្រូវបង់ប្រចាំឆ្នាំ។
  - **<u>ករណីទី២</u>**: ក្នុងករណីបង់ប្រាក់យឺតក្រោយថ្ងៃចូលរៀន≤**៦០ថ្ងៃ** នោះត្រូវទទួលការផាកពិន័យជាទឹកប្រាក់ចំនួន **$៣០ (សាមសិបដុល្លារ)** បូកបន្ថែមលើចំនួនទឹកប្រាក់ ដែលត្រូវបង់ប្រចាំឆ្នាំ។
  - **<u>ករណីទី៣</u>**: ក្នុងករណីបង់ប្រាក់យឺតក្រោយថ្ងៃចូលរៀន≤**៩០ថ្ងៃ** នោះត្រូវទទួលការផាកពិន័យជាទឹកប្រាក់ចំនួន **$៤០ (សែសិបដុល្លារ)** បូកបន្ថែមលើចំនួនទឹកប្រាក់ ដែលត្រូវបង់ប្រចាំឆ្នាំ។

ឃ/ ក្នុងករណីរៀនចប់ (គ្រប់កម្រិតសិក្សា) ទើបបានបង់លុយបង្គ្រប់ នោះត្រូវទទួលការផាកពិន័យចំនួន ៣០% **(សាមសិបភាគរយ)** បូកបន្ថែមលើចំនួនទឹកប្រាក់សរុបដែលត្រូវបង់តាមឆមាសនីមួយៗ

ង/ និស្សិតអាហារូបករណ៍ដែលមានបំណងសិក្សាមុខជំនាញបន្ថែម ក្រៅពីមុខជំនាញដែលទទួលបានអាហារូបករណ៍ និង/ឬផ្លាស់ប្តូរវេនសិក្សាដែលបានកំណត់ដោយសាកលវិទ្យាល័យ នឹងត្រូវបង់ថ្លៃសិក្សាលើជំនាញបន្ថែមនោះ

ច/ និស្សិតគ្រប់រូប ត្រូវធ្វើការបង់ថ្លៃលើឯកសារមួយចំនួនដូចមានចែងក្នុងគោលការណ៍លេខ ៣១០/១៥ សអអ/គក ស្តីពីការបង់ថ្លៃសិក្សា និងថ្លៃសេវាផ្សេងៗរបស់និស្សិតថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្ររង និងថ្នាក់ក្រោយបរិញ្ញាបត្រ

ឆ/ ចំពោះការស្នើឱ្យនិស្សិតផ្លាស់ប្តូរវេនសិក្សាដោយសាកលវិទ្យាល័យ និស្សិតទាំងអស់មិនត្រូវបានធ្វើការបង់ថ្លៃលើឯកសារប្តូរវេនសិក្សាទាំងនោះឡើយ។

## ប្រការ២៥.- ឯកសណ្ឋាននិស្សិត

និស្សិតត្រូវស្លៀកពាក់ឯកសណ្ឋាន ដែលកំណត់ដោយសាកលវិទ្យាល័យដូចខាងក្រោម ៖

ក/ **និស្សិតប្រុស ៖** ខោជើងវែងពណ៌ទឹកប៊ិចចាស់/ខ្មៅ និងអាវពណ៌ *សលាត ឬ ផ្ទៃមេឃលាត ស្បែកជើងឃ្លុប* ហើយត្រូវដាក់អាវក្នុងខោ និងត្រូវមានកាតសម្គាល់ខ្លួនជាដាច់ខាត។

ខ/ **និស្សិតស្រី ៖** សំពត់ពណ៌ទឹកប៊ិចចាស់/ខ្មៅ ត្រឹមជង្គង់ និងអាវពណ៌ *សលាត ឬ ផ្ទៃមេឃលាត ស្បែកជើងឃ្លុប ឬក្រវ៉ាត់កែង* ហើយត្រូវដាក់អាវក្នុងសំពត់ និងត្រូវមានកាតសម្គាល់ខ្លួនជាដាច់ខាត។

ខ/ **និស្សិតពេលយប់ ឬចុងសប្តាហ៍** ត្រូវស្លៀកពាក់សមរម្យ និងថ្លៃថ្នូរ។

- ហាមពាក់អាវយឺតអត់ក
- ហាមស្លៀកខោជើងខ្លី
- ត្រូវដាក់អាវក្នុងខោ ឬសំពត់
- និស្សិតប្រុសត្រូវពាក់ស្បែកជើងឃ្លុប និស្សិតស្រីត្រូវពាក់ស្បែកជើងឃ្លុប ឬ ក្រវ៉ាត់កែងនិងត្រូវមានកាតសម្គាល់ខ្លួនជាដាច់ខាត។

## ប្រការ២៦.- អំពីការសិក្សា

និស្សិតត្រូវអនុវត្តន៍តាមកាលវិភាគ និងកម្មវិធីសិក្សាដែលបានកំណត់ដោយសាកលវិទ្យាល័យ។ និស្សិតទាំងអស់ត្រូវមករៀនឱ្យបានទាន់ពេលវេលា។ ករណីសុំប្តូរពេលសិក្សាត្រូវមានមូលហេតុច្បាស់លាស់ និងសមរម្យ ជាពិសេសត្រូវមានលិខិតបញ្ជាក់ភ្ជាប់មកជាមួយ ទើបការិយាល័យសិក្សាពិនិត្យ និងសម្រេចឬមិនសម្រេចលើការស្នើសុំ។

## ប្រការ២៧.- ការព្យួរការសិក្សា

និស្សិតគ្រប់រូបអាចព្យួរការសិក្សាបានលុះត្រាតែ ៖

- ត្រូវបំពេញសំណុំឯកសារសុំព្យួរនៅការិយាល័យសិក្សាជាមុនសិនមុនថ្ងៃចូលរៀន ករណីបំពេញក្រោយថ្ងៃចូលរៀន ទឹកប្រាក់ដែលបានបង់រួចត្រូវចាត់ទុកជាមោឃៈ
- សម្រាប់ថ្នាក់បរិញ្ញាបត្រ អាចព្យួរការសិក្សាបានរយៈពេល០១ឆ្នាំ និងអាចព្យួរបានត្រឹមតែពីរដងគត់ក្នុងការសិក្សារយៈពេល០៤ឆ្នាំ

- សម្រាប់ថ្នាក់បរិញ្ញាបត្ររង អាចព្យួរការសិក្សាបានរយៈពេល០១ឆមាស និងអាចព្យួរការសិក្សាបានតែពីរដងគត់ក្នុងការសិក្សារយៈពេល០២ឆ្នាំ
- ក្នុងពេលព្យួរការសិក្សា និស្សិតគ្មានសិទ្ធិប្រឡងឆមាស ឬឡើងថ្នាក់បានឡើយ
- និស្សិតមិនអាចព្យួរការសិក្សាក្នុងរយៈពេលពីរឆ្នាំជាប់គ្នាបានទេ ក្នុងរយៈពេលសិក្សារហូតដល់ឆ្នាំបញ្ចប់ការសិក្សា
- ពេលសុំចូលរៀនវិញ និស្សិតត្រូវមកដាក់ពាក្យសុំចូលរៀន និងបង់ថ្លៃសិក្សាតាមការកំណត់របស់សាកលវិទ្យាល័យឱ្យបានមួយខែមុនពេលផុតកំណត់នៃរយៈពេលព្យួរការសិក្សា។ ប្រសិនបើនិស្សិតរូបណាពុំបានមកដាក់ពាក្យសុំចូលរៀនតាមកាលកំណត់ សាកលវិទ្យាល័យចាត់ទុកថា និស្សិតរូបនោះបានបោះបង់ការសិក្សារបស់ខ្លួន។

**ប្រការ២៨.- អំពីសីលធម៌**

ក/ សីលធម៌និស្សិតផ្តោតទៅលើការការពារមិនឱ្យនិស្សិតប្រព្រឹត្តល្មើសក្នុងការសិក្សា ឬប៉ុនប៉ងជួយដោយចេតនាឱ្យនិស្សិតផ្សេងទៀតប្រព្រឹត្តអំពើល្មើស។ ការប្រព្រឹត្តល្មើសក្នុងការសិក្សាមានដូចជា ៖

- ការក្លែងបន្លំព័ត៌មាន ៖ រួមបញ្ចូលការធ្វើរបាយការណ៍ពិសោធន៍ការសិក្សាស្រាវជ្រាវ ឬវិភាគស្ថិតិដោយមិនបានធ្វើឡើងដោយខ្លួនឯងផ្ទាល់ ឬការកែច្នៃ កែប្រែទិន្នន័យ រូបភាពខុសពីភាពជាក់ស្តែង ដើម្បីស្តែងឱ្យឃើញនូវលទ្ធផលដែលខ្លួនចង់បាន ហើយវារួមបញ្ចូលផងដែរនូវការក្លែងបន្លំឯកសារ និងលិខិតស្នាមទាក់ទងការសិក្សា។
- ការយកកិច្ចការអ្នកដទៃធ្វើជារបស់ខ្លួនឯង ៖ គឺជាការយកកិច្ចការដែលរៀបចំដោយអ្នកណាម្នាក់គេធ្វើជារបស់ខ្លួនឬការដាក់កិច្ចការដដែលនៅវគ្គសិក្សាផ្សេងៗគ្នាដោយគ្មានការអនុញ្ញាតជាមុនពីបុគ្គលិកសិក្សា។
- ការបើក ការពិភាក្សា ឬលួចចម្លងក្នុងពេលប្រឡង ៖ ពាក់ព័ន្ធនឹងសកម្មភាពដោយចំហរ ឬលាក់កំបាំងនូវការធ្វើកម្មសិទ្ធិមិនស្របច្បាប់ ឬជាការប្រើព័ត៌មានក្នុងសម្ភារកំណត់ត្រាជាវត្ថុជំនួយ ឬឧបករណ៍អេឡិចត្រូនិកណាមួយដែលត្រូវបានហាមឃាត់ក្នុងកំឡុងនៃការប្រឡង។ ការពិភាក្សា ការបើក ឬលួចចម្លងនេះបញ្ចូលផងដែរ នូវការចម្លងកិច្ចការប្រឡងរបស់និស្សិតណាម្នាក់ទៀត ការប្រគល់កិច្ចការប្រឡងក្នុងថ្នាក់ដែលមានការរៀបចំទុកជាមុនឱ្យអ្នកដទៃប្រឡងជំនួយ ឬការបំពាននីតិវិធីរដ្ឋបាលប្រឡង។ ក្នុងករណីនិស្សិតបើក ឬលួចចម្លងក្នុងពេលប្រឡងនឹងត្រូវបានចាត់ទុកថាប្រព្រឹត្តបទល្មើសក្នុងការសិក្សានេះផងដែរ។
- ការលួចចម្លងស្នាដៃ ៖ មានន័យថាជាការប្រើប្រាស់នូវព័ត៌មាន ពាក្យពេចន៍ ឃ្លាគំនិត ដោយគ្មានការទទួលស្គាល់នូវប្រភពព័ត៌មាន ហើយក៏រាប់បញ្ចូលផងនូវការយកស្នាដៃអ្នកនិពន្ធណាមួយមកធ្វើជារបស់ខ្លួន។
- ការប្រកួតប្រជែងមិនស្មោះត្រង់ ដោយយក ឬបន្លំកិច្ចការស្រាវជ្រាវ ឧបករណ៍ស្រាវជ្រាវ អង្គចងចាំ (Hard Disk or Flash Drive) ជាដើម ដែលជារបស់និស្សិតដទៃ និងសំដៅលើចេតនាក្នុងការធ្វើឱ្យខូចខាតនូវកិច្ចខិតខំប្រឹងប្រែង ឬការធ្វើឱ្យបាត់បង់នូវសម្ភារ និងធនធានសិក្សាចាំបាច់នានាដូចជាសៀវភៅសិក្សាឬកំណត់ត្រានានាជាដើម។
- ការមិនយកចិត្តទុកដាក់ក្នុងការចូលរួមបំពេញកិច្ចការជាក្រុមឬការធ្វើការងារជាក្រុមមិនអស់អំពីលទ្ធភាព៖

សំដៅដល់ការមិនចូលរួម ឬចូលរួមមិនពេញលេញក្នុងការស្រាវជ្រាវជាក្រុម ដែលផ្ទុយទៅវិញលទ្ធផលទទួលបានគឺពិន្ទុស្មើគ្នា។ ក្នុងករណីមានបណ្តឹងអំពីសមាជិកក្រុមណាមួយ ឬច្រើនគ្នានិស្សិតនោះនឹងអាចទទួលរងនូវការប្រព្រឹត្តល្មើសក្នុងការសិក្សា។

- ការប្រើប្រាស់បណ្តាញអ៊ីនធឺណិត និងឧបករណ៍អេឡិចត្រូនិកផ្ទុយពីការសិក្សាស្រាវជ្រាវ ៖ ភាពមិនសមស្របក្នុងការប្រើប្រាស់បណ្តាញអ៊ីនធឺណែត និងឧបករណ៍អេឡិចត្រូនិច សំដៅដល់ការប្រើប្រាស់បណ្តាញ និងឧបករណ៍នោះក្នុងបរិវេណសាកលវិទ្យាល័យ ក្នុងគោលដៅមិនបម្រើដល់ការសិក្សា ជាពិសេសប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ សុវត្ថិភាព សន្តិសុខ ភាពជាឯកជនរបស់អ្នកដទៃ និងបង្កការរំខានដល់ការសិក្សា ឬពេលកំពុងប្រឡង។
- ការប្រើប្រាស់ឥទ្ធិពល ឬការគំរាមកំហែងនាំឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពសេចក្តីថ្លៃថ្នូរ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវផ្សេងៗទៀតដែលផ្ទុយពីច្បាប់ និងគោលការណ៍សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប
- ការសូកប៉ាន់ ការទទួលសំណូក ដើម្បីទទួលបានផលប្រយោជន៍ទាក់ទងទៅនឹងសកម្មភាពសិក្សាស្រាវជ្រាវទាំងក្នុង និងក្រៅសាកលវិទ្យាល័យ។

ខ/ សីលធម៌ក្នុងថ្នាក់រៀន ៖

- និស្សិតត្រូវគោរពពេលវេលាតាមកាលវិភាគរបស់សាកលវិទ្យាល័យឱ្យបានម៉ឺងម៉ាត់។ ករណីមកយឺតលើសពីដប់ប្រាំ (១៥)នាទី មិនអនុញ្ញាតឱ្យចូលរៀនឡើយ។ លើកលែងមានការអនុញ្ញាតពីការិយាល័យសិក្សា និង/ឬ គ្រូទទួលបន្ទុក
- ពេលម៉ោងសិក្សា និស្សិតត្រូវយកចិត្តទុកដាក់រៀនសូត្រប្រកបដោយសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយ
- ពេលសាស្ត្រាចារ្យ ឬភ្ញៀវអញ្ជើញចូលក្នុងថ្នាក់រៀន និស្សិតទាំងអស់ត្រូវក្រោកឈរ រក្សាភាពស្ងៀមស្ងាត់ និងសម្តែងនូវអាកប្បកិរិយាថ្លៃថ្នូរ
- ពេលសាស្ត្រាចារ្យអវត្តមាន ឬមកយឺតរយៈពេលលើសពីដប់ប្រាំ (១៥)នាទី និស្សិតក្នុងថ្នាក់ត្រូវរក្សាភាពស្ងៀមស្ងាត់ ហើយប្រធាន អនុប្រធានថ្នាក់ ឬតំណាងនិស្សិតម្នាក់មកទំនាក់ទំនង និងទទួលព័ត៌មានពីការិយាល័យសិក្សា ឬមហាវិទ្យាល័យសាមី
- ពេលចេញលេងនិស្សិតត្រូវប្រកាន់អាកប្បកិរិយាសមរម្យ ហើយមិនត្រូវប្រលែងគ្នា ស្រែកឡូឡា ឬឈ្លោះប្រកែកគ្នាឡើយ
- ពេលចេញក្រៅថ្នាក់ ឬចេញទៅផ្ទះមុនម៉ោង ដោយមានធុរៈចាំបាច់ ឬមានជំងឺផ្ទាល់ខ្លួន និស្សិតត្រូវសុំអនុញ្ញាតពីសាស្ត្រាចារ្យដែលកំពុងបង្រៀន
- ក្នុងពេលកំពុងសិក្សា និស្សិតមិនត្រូវនាំមិត្តភក្តិ ឬសាច់ញាតិពីខាងក្រៅមកចូលអង្គុយក្នុងថ្នាក់របស់ខ្លួនឡើយ
- ហាមប្រើប្រាស់ទូរសព្ទដៃ ឬវិទ្យុទាក់ទងក្នុងពេលសិក្សា និងក្នុងពេលប្រឡង។

គ/ សីលធម៌ក្នុងបរិវេណសាកលវិទ្យាល័យ និស្សិតទាំងអស់មិនត្រូវ ៖

- ធ្វើសកម្មភាពនយោបាយឡើយ
- ពាក់ម៉ាស់ និងមួកសុវត្ថិភាព
- ជក់បារី សេពគ្រឿងស្រវឹង និងប្រើប្រាស់ ឬជួញដូរគ្រឿងញៀនជាដាច់ខាត

- យកអាវុធជាតិផ្ទុះគ្រប់ប្រភេទ គ្រឿងញៀន គ្រឿងស្រវឹង ចូលមកក្នុងបរិវេណសាកលវិទ្យាល័យ ឡើយ
- លេងល្បែងស៊ីសង ឬប្រព្រឹត្តអំពើពាលាដែលខុសច្បាប់និងប្រពៃណីជាតិ
- ធ្វើសកម្មភាពទាំងឡាយណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងផលប្រយោជន៍របស់សាកលវិទ្យាល័យ និងសង្គមជាតិ
- ស្រែកឡូឡា ឬប្រើពាក្យអាសអាភាស អាសគ្រាម និងអាកប្បកិរិយាមិនថ្លៃថ្នូរដែលប្រាសចាកពីប្រពៃណីជាតិ
- ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ និងបាត់បង់សោភ័ណ្ឌភាព បរិស្ថានសាកលវិទ្យាល័យ ដោយប្រការណាមួយឡើយ។

ឃ/ រាល់បាតុភាពអសកម្មណាមួយ ត្រូវរាយការណ៍មកកាន់ការិយាល័យរដ្ឋបាល ឬភ្នាក់ងារសន្តិសុខជាបន្ទាន់ ដូចជា៖

- មានអគ្គិភ័យ
- និស្សិតមានជំងឺដែលត្រូវសង្គ្រោះបន្ទាន់
- និស្សិតឈ្លោះប្រកែក ឬវាយតប់គ្នា
- មានអំពើចោរកម្ម
- មានសមាសភាពជនមិនល្អចូលក្នុងសាកលវិទ្យាល័យ។

**ប្រការ២៩.- ករណីនិស្សិតអវត្តមាន ឥតច្បាប់**

ក/ ការឈប់ឥតច្បាប់ចំនួនបួន (៤)ដង ក្នុងមុខវិជ្ជាណាមួយ នឹងត្រូវទទួលការព្រមានលើកទី១ ដោយក្រុមប្រឹក្សាវិន័យ ឬការិយាល័យសិក្សា និង/ឬ ជូនដំណឹងដល់អាណាព្យាបាល

ខ/ ការឈប់ឥតច្បាប់ចំនួនប្រាំពីរ (៧)ដង ក្នុងមុខវិជ្ជាណាមួយ នឹងត្រូវទទួលការព្រមានលើកទី២ដោយក្រុមប្រឹក្សាវិន័យ ឬការិយាល័យសិក្សា និងអញ្ជើញអាណាព្យាបាលមកទទួលដំណឹងជាលើកចុងក្រោយ

គ/ ការឈប់ឥតច្បាប់ចំនួនដប់ (១០)ដង ក្នុងមុខវិជ្ជាណាមួយ ត្រូវកំណត់ថាធ្លាក់លើមុខវិជ្ជានោះដោយស្វ័យប្រវត្តិ ហើយត្រូវរង់ចាំការប្រឡងសងឡើងវិញទៅតាមកាលបរិច្ឆេទ ដែលកំណត់ដោយសាកលវិទ្យាល័យ

ឃ/ ការឈប់ឥតច្បាប់សរុបក្នុងមួយឆមាសចំនួនដប់ប្រាំ (១៥)ដង ក្នុងមុខវិជ្ជាណាមួយ ត្រូវកំណត់ថាធ្លាក់លើមុខវិជ្ជានោះដោយស្វ័យប្រវត្តិ ហើយត្រូវបង់ថ្លៃសិក្សារៀនឡើងវិញលើមុខវិជ្ជាដែលធ្លាក់នោះ

ង/ ការឈប់ឥតច្បាប់ចំនួនដប់ប្រាំ (១៥)ដង លើមុខវិជ្ជាចំនួន០៣ ក្នុងឆមាសណាមួយ ត្រូវកំណត់ថាធ្លាក់ដោយស្វ័យប្រវត្តិ ហើយត្រូវបង់ថ្លៃសិក្សា និងរៀនត្រួតឆមាសនោះ។

**ប្រការ៣០.- ករណីនិស្សិតអវត្តមាន មានច្បាប់**

ក/ និស្សិតត្រូវសុំច្បាប់ជាមុននៅការិយាល័យសិក្សា ដោយបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់

ខ/ ការឈប់មានច្បាប់ចំនួនដប់ (១០)ដង ក្នុងមុខវិជ្ជាណាមួយ នឹងត្រូវទទួលការព្រមានដោយក្រុមប្រឹក្សាវិន័យ ឬការិយាល័យសិក្សា និង/ឬ ជូនដំណឹងដល់អាណាព្យាបាល

គ/ ការឈប់មានច្បាប់ចំនួនដប់ប្រាំ (១៥)ដង ក្នុងមុខវិជ្ជាណាមួយ ត្រូវកំណត់ថាធ្លាក់លើមុខវិជ្ជានោះដោយស្វ័យប្រវត្តិ ហើយត្រូវរង់ចាំការប្រឡងសងឡើងវិញទៅតាមកាលបរិច្ឆេទ ដែលកំណត់ដោយសាកលវិទ្យាល័យ

ឃ/ ការឈប់មានច្បាប់លើសចំនួនដប់ប្រាំ (១៥)ដង ក្នុងមុខវិជ្ជាចំនួន០៣ ត្រូវកំណត់ថាធ្លាក់ដោយស្វ័យប្រវត្តិ ហើយត្រូវបង់ថ្លៃសិក្សា និងរៀនត្រួតឆមាសនោះ។

**ប្រការ៣១.- ការប្រឡង**

ចំពោះនិស្សិតដែលសិក្សានៅក្នុងឯកទេសវិទ្យាសាស្ត្រកុំព្យូទ័រ បច្ចេកវិទ្យាព័ត៌មាន ការគ្រប់គ្រងប្រព័ន្ធព័ត៌មាន ធនាគារនិងហិរញ្ញវត្ថុ ពាណិជ្ជកម្មអន្តរជាតិ សេដ្ឋកិច្ច វិទ្យាសាស្ត្រនយោបាយ អភិវឌ្ឍន៍សហគមន៍ គ្រប់គ្រងធនធានមនុស្ស គ្រប់គ្រងសណ្ឋាគារនិងទេសចរណ៍ ម៉ាឃីទីង គណនេយ្យ នីតិសាធារណៈ គ្រប់គ្រងនីតិឯកជន រដ្ឋបាលសាធារណៈ ទំនាក់ទំនងអន្តរជាតិ និងអក្សរសាស្ត្រចិន ដែលប្រឡងធ្លាក់ចាប់ពី **០៤មុខវិជ្ជាឡើងទៅ** នឹងត្រូវរៀនត្រួតឆមាសនោះឡើងវិញ លើកលែងថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន។ ដោយឡែកចំពោះនិស្សិតដែលសិក្សានៅក្នុងឯកទេស ភាសាអង់គ្លេស ដែលប្រឡងធ្លាក់ចាប់ពី **០៣មុខវិជ្ជាឡើងទៅ** នឹងត្រូវរៀនត្រួតឆមាសនោះឡើងវិញ លើកលែងថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន។

នៅពេលប្រឡងនិស្សិតគ្រប់រូបត្រូវគោរពបទបញ្ជាផ្ទៃក្នុង និងសេចក្តីណែនាំនានារបស់សាកលវិទ្យាល័យ ដូចខាងក្រោម៖

ក/ អង្គុយតាមលេខតុដែលកំណត់ដោយគណៈកម្មការប្រឡង

ខ/ បំពេញក្បាលសន្លឹកកិច្ចការឱ្យបានគ្រប់ចំណុចតាមការណែនាំរបស់គណៈកម្មការប្រឡង។ ករណីនិស្សិតមិនបានបំពេញក្បាលសន្លឹកកិច្ចការនោះត្រូវបានពិន្ទុសូន្យ

គ/ ចុះហត្ថលេខាលើបញ្ជីវត្តមានប្រឡង

ឃ/ ប្រើប្រាស់ទឹកប៊ិចពណ៌ខៀវ ករណីផ្ទុយត្រូវមានការអនុញ្ញាតពីអនុរក្ស និងមិនត្រូវប្រើទឹកលុប

ង/ រក្សាភាពស្ងៀមស្ងាត់ អង្គុយឱ្យបានសមរម្យ

ច/ ហាមងាកសួរអ្នកជិតខាង

ឆ/ ហាមចេញក្រៅបន្ទប់ក្នុងពេលប្រឡង លើកលែងតែមានការអនុញ្ញាតពីអនុរក្ស

ជ/ ហាមយកសំណៅឯកសារផ្សេងៗចូលក្នុងបន្ទប់ប្រឡង លើកលែងតែមានការអនុញ្ញាតពីគណៈកម្មការប្រឡង

ឈ/ **ហាមប្រើប្រាស់ទូរសព្ទ ឬវិទ្យុទាក់ទង និងទឹកលុប**

ញ/ ត្រូវអនុវត្តន៍តាមការណែនាំរបស់គណៈកម្មការត្រួតពិនិត្យ និងអនុរក្ស

ដ/ នៅពេលចប់ម៉ោង និស្សិតត្រូវប្រគល់សន្លឹកកិច្ចការទៅឱ្យអនុរក្ស ទោះបីជាសន្លឹកកិច្ចការនោះគ្មានសរសេរចម្លើយក៏ដោយ

ឋ/ មិនអនុញ្ញាតឱ្យចូលប្រឡងក្នុងករណី៖

- មកយឺតលើសពីដប់ប្រាំ (១៥) នាទី
- មានយកអាវុធជាតិផ្ទុះមកជាមួយ

- គ្មានកាត ឬប័ណ្ណសម្គាល់ខ្លួននិស្សិត
- គ្មានបង្កាន់ដៃបង់ប្រាក់ ក្នុងករណីប្រឡងសង។

**ប្រការ៣២.- ករណីកំហុសក្នុងពេលប្រឡង**

ក/ មានឯកសារ ឬសំណៅផ្សេងៗនៅពេលប្រឡង ៖

- ត្រូវទទួលការព្រមានដោយដក ៥ពិន្ទុ ក្នុងករណីចាប់បានលើកទី១
- ត្រូវទទួលការព្រមានដោយដក ១០ពិន្ទុ ក្នុងករណីចាប់បានលើកទី២
- បញ្ឈប់ការប្រឡងលើមុខវិជ្ជានោះ ក្នុងករណីចាប់បានលើកទី៣។

ខ/ បោះសំណៅឯកសារទៅឱ្យមិត្តភក្តិទោះក្នុងរូបភាពណាក៏ដោយ ៖

- ត្រូវទទួលការព្រមានដោយដក ៥ពិន្ទុ ក្នុងករណីចាប់បានលើកទី១
- ត្រូវទទួលការព្រមានដោយដក ១០ពិន្ទុ ក្នុងករណីចាប់បានលើកទី២
- បញ្ឈប់ការប្រឡងលើមុខវិជ្ជានោះ ក្នុងករណីចាប់បានលើកទី៣។

គ/ **ដក ១០ពិន្ទុ ករណីអង្គុយខុសលេខតុរបស់ខ្លួន និងបញ្ឈប់ពីការប្រឡងក្នុងករណីមិនគោរពតាមការណែនាំរបស់អនុរក្ស**

ឃ/ ត្រូវបានពិន្ទុសូន្យ ក្នុងករណីនិស្សិតមិនបានប្រគល់សន្លឹកកិច្ចការដល់អនុរក្ស នៅពេលបញ្ចប់ការប្រឡង

ង/ ត្រូវបានពិន្ទុសូន្យ ក្នុងករណីនិស្សិតលួចមើលសំណៅឯកសារក្រៅបន្ទប់ប្រឡង

ច/ ត្រូវបានពិន្ទុសូន្យ ក្នុងករណីនិស្សិតមិនបានចុះហត្ថលេខាលើបញ្ជីវត្តមានប្រឡង

ឆ/ ត្រូវបញ្ឈប់ពីការប្រឡងជាបន្ទាន់ និងបញ្ជូនទៅក្រុមប្រឹក្សាវិន័យដើម្បីវិនិច្ឆ័យករណីនិស្សិតដែលសម្ដែងអាកប្បកិរិយាមិនសមរម្យ ប្រើពាក្យសំដីមិនថ្លៃថ្នូរ និងស្រែកឡូឡា ដែលនាំឱ្យរំខានក្នុងពេលប្រឡង

ជ/ ករណីបង្កទំនាស់ជាមួយគណៈកម្មការប្រឡង ត្រូវទទួលពិន័យចាប់ពីបញ្ឈប់ការប្រឡងរហូតដល់បណ្ដេញចេញពីសាកលវិទ្យាល័យជាស្ថាពរ ដោយផ្អែកទៅលើទំហំនៃអំពើប្រព្រឹត្តជាក់ស្ដែងដែលបានបង្កឡើង

ឈ/ ករណីហែកចោលសន្លឹកកិច្ចការប្រឡង ៖

- បញ្ឈប់ពីការប្រឡងគ្រប់មុខវិជ្ជាទាំងអស់ ក្នុងសម័យប្រឡងដែលកំពុងប្រព្រឹត្តទៅ
- ការប្រព្រឹត្តក្នុងករណីដដែលជាលើកទី២ទៀត ត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតនៃសាកលវិទ្យាល័យជាស្ថាពរដោយគ្មានលក្ខខណ្ឌ និងបិទផ្សាយជាសាធារណៈ។

ញ/ ករណីនិស្សិតប្រឡងជំនួស ឬប្រឡងជួយនិស្សិតម្នាក់ទៀត និស្សិតទាំងពីរនេះត្រូវទទួលពិន័យពីក្រុមប្រឹក្សាវិន័យ ចាប់ពីការបញ្ឈប់ការប្រឡងគ្រប់មុខវិជ្ជាទាំងអស់ក្នុងសម័យប្រឡង ដែលកំពុងប្រព្រឹត្តទៅរហូតដល់បណ្ដេញចេញពីសាកលវិទ្យាល័យជាស្ថាពរដោយគ្មានលក្ខខណ្ឌ។

### ប្រការ៣៣.- ការប្រឡងសង និងកាលបរិច្ឆេទនៃការប្រឡងសង

ក/ *ការប្រឡងបញ្ចប់មុខវិជ្ជាក្នុងឆមាសនីមួយៗ ត្រូវបានរៀបចំ និងគ្រប់គ្រងដោយផ្ទាល់ពីសាស្ត្រាចារ្យទទួលបន្ទុកមុខវិជ្ជាដែលបានបង្រៀន ប៉ុន្តែមានការចូលរួមជួយសហការ និងអប្បមាទ ពីផ្នែកកិច្ចការប្រឡងនៃការិយាល័យសិក្សា និងព្រឹទ្ធបុរសមហាវិទ្យាល័យសាមី និង/ឬក្រុមប្រឹក្សាវិន័យ។*

ខ/ ការប្រឡងសងក្នុងឆមាសនីមួយៗ ត្រូវរៀបចំឡើងជា **០៣លើក** និងត្រូវបានកំណត់ដូចខាងក្រោម ៖

- ***លើកទី១*** ត្រូវរៀបចំឡើងដោយការិយាល័យសិក្សា បន្ទាប់ពីប្រកាសលទ្ធផលប្រឡងរួចរយៈពេល ០២សប្តាហ៍
- ***លើកទី២*** ត្រូវរៀបចំឡើងដោយព្រឹទ្ធបុរសមហាវិទ្យាល័យសាមី ដោយសហការជាមួយការិយាល័យសិក្សា បន្ទាប់ពីប្រកាសលទ្ធផលប្រឡងសងលើកទី០១ រួចរយៈពេល០១សប្តាហ៍
- ***លើកទី៣*** ត្រូវរៀបចំឡើងដោយព្រឹទ្ធបុរសមហាវិទ្យាល័យសាមី ដោយសហការជាមួយការិយាល័យសិក្សា បន្ទាប់ពីប្រកាសលទ្ធផលប្រឡងសងលើកទី០២រួច ដោយនិស្សិតត្រូវសិក្សាបំប៉នជាមួយសាស្ត្រាចារ្យនៅមុខវិជ្ជាដែលធ្លាក់ តាមការកំណត់របស់ព្រឹទ្ធបុរស បន្ទាប់មកទើបធ្វើការប្រឡងសងជាលើកចុងក្រោយក្នុងឆមាសនោះ។

គ/ ចំពោះកាលបរិច្ឆេទនៃការប្រឡងសងឆមាសនីមួយៗត្រូវបានកំណត់ដោយការិយាល័យសិក្សាតាមរយៈសេចក្តីជូនដំណឹង។

ឃ/ និស្សិតដែលពុំទាន់បានប្រឡងសងតាមមុខវិជ្ជាដែលខ្លួនបានធ្លាក់ចាប់ពី០១មុខវិជ្ជាឡើងទៅ ក្នុងឆ្នាំសិក្សារបស់ខ្លួន គឺមិនត្រូវបានអនុញ្ញាតឱ្យប្រឡងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ឬថ្នាក់បរិញ្ញាបត្ររង (Comprehensive Exam) ឡើយ។

### ប្រការ៣៤.- ការប្រឡងសងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្ររង

(Comprehensive Exam)

ក/ និស្សិតដែលមានសិទ្ធិប្រឡងសង តែ០១លើកគត់ ក្រោយរយៈពេល៤៥ថ្ងៃ (អាចផ្លាស់ប្តូរតាមស្ថានភាពជាក់ស្តែង) នៃការប្រកាសលទ្ធផលបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ឬថ្នាក់បរិញ្ញាបត្ររង។

ខ/ ក្នុងករណីធ្លាក់លើការប្រឡងសងនេះ និស្សិតត្រូវប្រឡងបញ្ចប់ការសិក្សាជាមួយនិស្សិតជំនាន់ក្រោយក្នុងឆ្នាំសិក្សាបន្ទាប់។

គ/ ការិយាល័យសិក្សា ត្រូវកំណត់កាលបរិច្ឆេទជាក់លាក់នៃការប្រឡងសងនេះ តាមរយៈសេចក្តីជូនដំណឹង។

### ប្រការ៣៥.- ករណីធ្លាក់ដោយស្វ័យប្រវត្តិ

និស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បរិញ្ញាបត្រទាំងអស់ត្រូវបំពេញតាមលក្ខខណ្ឌខាងលើជាដាច់ខាតករណីមិនបានបំពេញក្នុងលក្ខខណ្ឌណាមួយត្រូវធ្លាក់ដោយស្វ័យប្រវត្តិ ដោយមានការកំណត់តាមមហា-វិទ្យាល័យ និងឯកទេសដូចខាងក្រោម ៖

ក -មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា (គ្រប់ឯកទេសទាំងអស់)

- អវត្តមានលើសពី ១០ ដង មិនអនុញ្ញាតឱ្យប្រឡង
- និស្សិតមិនបានធ្វើកិច្ចការស្រាវជ្រាវ និង/ឬ មិនមានពិន្ទុកិច្ចការស្រាវជ្រាវ
- និស្សិតមិនបានប្រឡងពាក់កណ្ដាលឆមាស
- និស្សិតករណីនិស្សិតមិនបានមកប្រឡងបញ្ចប់ឆមាស។

ខ -មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍ (គ្រប់ឯកទេសទាំងអស់)

- អវត្តមានលើសពី ១០ ដង មិនអនុញ្ញាតឱ្យប្រឡង
- និស្សិតមិនបានធ្វើកិច្ចការស្រាវជ្រាវ និង/ឬ មិនមានពិន្ទុកិច្ចការស្រាវជ្រាវ
- និស្សិតមិនបានប្រឡងពាក់កណ្ដាលឆមាស
- និស្សិតករណីនិស្សិតមិនបានមកប្រឡងបញ្ចប់ឆមាស។

គ -មហាវិទ្យាល័យសង្គមសាស្ត្រ និងសេដ្ឋកិច្ច (គ្រប់ឯកទេសទាំងអស់)

- អវត្តមានលើសពី ១០ ដង មិនអនុញ្ញាតឱ្យប្រឡង
- និស្សិតមិនបានធ្វើកិច្ចការស្រាវជ្រាវ និង/ឬ មិនមានពិន្ទុកិច្ចការស្រាវជ្រាវ
- និស្សិតមិនបានប្រឡងពាក់កណ្ដាលឆមាស
- និស្សិតករណីនិស្សិតមិនបានមកប្រឡងបញ្ចប់ឆមាស។

ឃ -មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ (គ្រប់ឯកទេសទាំងអស់)

- អវត្តមានលើសពី ១០ ដង មិនអនុញ្ញាតឱ្យប្រឡង
- និស្សិតមិនបានធ្វើកិច្ចការស្រាវជ្រាវ និង/ឬ មិនមានពិន្ទុកិច្ចការស្រាវជ្រាវ
- និស្សិតករណីនិស្សិតមិនបានមកប្រឡងបញ្ចប់ឆមាស។

ង -មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (គ្រប់ឯកទេសទាំងអស់)

- អវត្តមានលើសពី ១០ ដង មិនអនុញ្ញាតឱ្យប្រឡង
- និស្សិតមិនបានធ្វើកិច្ចការស្រាវជ្រាវ និង/ឬ មិនមានពិន្ទុកិច្ចការស្រាវជ្រាវ
- និស្សិតករណីនិស្សិតមិនបានមកប្រឡងបញ្ចប់ឆមាស។

**ប្រការ៣៦.- សិទ្ធិរបស់និស្សិត**

និស្សិតមានសិទ្ធិស្របច្បាប់ និងបុព្វសិទ្ធិបន្ថែម ព្រមទាំងមិនតម្រូវឱ្យមានការដាក់ពិន័យដោយបានប្រើប្រាស់សិទ្ធិ និងបុព្វសិទ្ធិដូចខាងក្រោម ៖

- សិទ្ធិទទួលបានបរិយាកាសសិក្សាល្អសំដៅដល់លទ្ធផល និងការទទួលបាននូវឱកាសក្នុងការ ប្រើប្រាស់ដោយស្មើភាពគ្នានូវសេវាគាំទ្រនានា និងជំនួយពីសាកលវិទ្យាល័យដើម្បីជានាឱ្យបាននូវការសិក្សាល្អប្រសើរដែលជំរុញលើកទឹកចិត្តនិងធ្វើឱ្យប្រសើរឡើងនូវការសិក្សាស្រាវជ្រាវ។ លើសពីនេះទៀត និស្សិតទាំងអស់ក៏មានសិទ្ធិប្រើប្រាស់សម្ភារ និងធនធានសិក្សារបស់សាកលវិទ្យាល័យផងដែរ ដូចជាបន្ទប់ស្ដាប់ភាសា បន្ទប់អនុវត្តកុំព្យូទ័រ និងបណ្ណាល័យជាដើម។ល។
- សិទ្ធិទទួលបានសមភាពក្នុងការវាយតម្លៃការសិក្សា សំដៅដល់សិទ្ធិក្នុងការវាយតម្លៃលើការសិក្សាដោយផ្ដោតលើលក្ខណៈវិនិច្ឆ័យ ដែលបានចែងក្នុងគោលការណ៍នៃការវាយតម្លៃការសិក្សារបស់និស្សិតពីបុគ្គលិកសិក្សាប្រកបដោយមនសិការ និងគ្មានឥទ្ធិពលនៃអគតិទាំង៤ គឺភ័យាគតិ ឆន្ទាគតិ

មោហាគតិ និងទោសោគតិ។ បន្ថែមលើនេះទៀត និស្សិត មានសិទ្ធិដឹងឮ និងធ្វើការតវ៉ានូវពិន្ទុនៃការវាយតម្លៃជាប្រចាំរបស់ខ្លួនមុនដំណាច់ឆមាស និងពិន្ទុនៃការវាយឱ្យតម្លៃសរុបនៅពេលបញ្ចប់ឆមាសនីមួយៗ។

- សិទ្ធិចូលរួមក្នុងការងារនានារបស់សាកលវិទ្យាល័យមានន័យថា សាកលវិទ្យាល័ត្រូវបញ្ចូលតំណាងនិស្សិត ឬអតីតនិស្សិតចូលរួមក្នុងសកម្មភាពនានាដែលពាក់ព័ន្ធ នឹងការសិក្សាក៏មានសិទ្ធិផងដែរចំពោះការវាយតម្លៃបុគ្គលិកសិក្សា។
- សិទ្ធិសេរីភាពពីការរើសអើង និងការបៀតបៀនផ្លូវភេទសំដៅដល់សិទ្ធិដែលទទួលនូវការពារពីការបៀតបៀនផ្លូវភេទ និងការប្រព្រឹត្តមិនស្មើភាពមកលើខ្លួនដោយសារតែពូជសាសន៍ អាយុ សាសនា យេនឌ័រ ពណ៌សម្បុរ និងពិការភាព ដែលត្រូវបានការពារដោយច្បាប់។
- សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិមានន័យថានិស្សិតទាំងអស់មានសិទ្ធិត្រួតពិនិត្យ និងប្រាស្រ័យទាក់ទងនូវគំនិតរបស់ខ្លួនដោយមធ្យោបាយស្របច្បាប់។ និស្សិតនឹងមិនតម្រូវឱ្យមានការដាក់ទណ្ឌកម្មការសិក្សា ឬអាកប្បកិរិយាដោយសារតែការប្រើសេរីភាពដែលការពារដោយរដ្ឋធម្មនុញ្ញ។
  - គោរពម៉ោងពេលសិក្សាដោយអនុវត្តតាមកាលវិភាគសិក្សា
  - ត្រូវមានសម្ភារសិក្សាជាចាំបាច់ពេលចូលសិក្សាក្នុងថ្នាក់រៀន
  - ចូលរួមគ្រប់សកម្មភាពសិក្សា និងស្រាវជ្រាវដើម្បីទទួលបានក្រេឌីតដោយបំពេញទៅតាមលក្ខខណ្ឌ និងនិតិវិធីនៃប្រព័ន្ធផ្តល់ពិន្ទុនិងនិទ្ទេសលើការសិក្សារបស់និស្សិត
  - មិនត្រូវបញ្ជូន ទទួលទូរសព្ទ ឬបង្កសម្លេងរំខានក្នុងពេលសិក្សា
  - ចូលរួមសកម្មភាពមហាវិទ្យាល័យ និងសហគមន៍ ដែលជាផ្នែកមួយនៃសកម្មភាពសិក្សា និងស្រាវជ្រាវ។
- សិទ្ធិទទួលឯករាជ្យ និងការសម្ងាត់ក្នុងការសិក្សានិស្សិតទាំងអស់ មានសិទ្ធិចូលរួមក្នុងគ្រប់សកម្មភាពសិក្សា ហើយលទ្ធផលសិក្សា និងព័ត៌មានឯកជនរបស់និស្សិតនឹងមិនត្រូវលាតត្រដាងដោយបុគ្គលិកសិក្សា ឬបុគ្គលិករដ្ឋបាលសាកលវិទ្យាល័យលើកលែងតែអ្នកមានសិទ្ធិចំពោះព័ត៌មានបែបនេះដែលកំណត់ដោយច្បាប់ ឬគោលនយោបាយសាកលវិទ្យាល័យ។
- សិទ្ធិផ្ទេរក្រេឌីតមានន័យថា និស្សិតទាំងអស់មានសិទ្ធិក្នុងការផ្លាស់ប្តូរជំនាញ ឯកទេស ផ្ទេរក្រេឌីតសិក្សាពីមហាវិទ្យាល័យមួយទៅមហាវិទ្យាល័យមួយនៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ឬផ្ទេរក្រេឌីតទៅកាន់គ្រឹះស្ថានឧត្តមសិក្សាផ្សេងៗបាន។ ការអនុវត្តនេះនឹងត្រូវអនុវត្តតាមប្រកាសទី១២ ឬតាមគោលនយោបាយស្តីពីការផ្ទេរ និងទទួលស្គាល់ក្រេឌីតនៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប
- សិទ្ធិព្យួរការសិក្សាមានន័យថា និស្សិតទាំងអស់អាចព្យួរការសិក្សា និងនិវត្តន៍ការសិក្សា យោងទៅតាមការចាំបាច់របស់និស្សិត ដែលការអនុវត្តត្រូវស្របតាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា។
- សិទ្ធិសុំអនុញ្ញាតច្បាប់មានន័យថា និស្សិតទាំងអស់អាចស្នើសុំច្បាប់ឈប់សម្រាកដោយមានហេតុផលសមស្រប ទាក់ទងនឹងបញ្ហាផ្ទាល់ខ្លួន ឬការងារ។ រយៈពេលនៃការឈប់សម្រាកនានាត្រូវមានការសម្រេច និងឯកភាពពីផ្នែកកិច្ចការនិស្សិតនៃការិយាល័យសិក្សា។

- សិទ្ធិទទួលបាននូវការការពារស្នាដៃស្រាវជ្រាវមានន័យថា និស្សិតអាចទទួលបាននូវការការពារ មិនឱ្យមានការផ្សព្វផ្សាយដោយគ្មានការព្រមព្រៀងពីសាមីនិស្សិត នូវពត៌មានដែលមាននៅក្នុងរបាយការណ៍សិក្សា ឬស្នាដៃស្រាវជ្រាវរបស់ខ្លួន។

## ជំពូកទី ៦
## តួនាទី និងការទទួលខុសត្រូវរបស់និស្សិត

**ប្រការ ៣៧**.- និស្សិតត្រូវបានផ្តល់នូវកិត្តិយស សេចក្តីថ្លៃថ្នូរ និងការគោរព។ ជាមួយគ្នានេះនិស្សិត ត្រូវមានតួនាទី និងការទទួលខុសត្រូវការសិក្សាស្រាវជ្រាវ និងប្រតិបត្តិតាមវិធានវិន័យ និងវិធាននៃការប្រព្រឹត្តល្មើសវិន័យនិស្សិតដែលកំណត់ដោយសាកលវិទ្យាល័យក្នុងកំឡុងពេលសិក្សា។

**ប្រការ ៣៨**.- និស្សិតត្រូវគោរពតាមវិធានទូទៅនៃតួនាទី និងការទទួលខុសត្រូវចំពោះការសិក្សាស្រាវជ្រាវរួមមាន៖ បញ្ហាសិក្សាជាបឋម និងទទួលដំណោះស្រាយទៅតាមគោលការណ៍និតិវិធីនៃវិធានវិន័យ និងវិធាននៃការប្រព្រឹត្តល្មើសវិន័យនិស្សិត។

**ប្រការ ៣៩**.- និស្សិតត្រូវ គោរពតាមវិធានការទូទៅរបស់សាកលវិទ្យាល័យ រួមមាន៖
- ត្រូវគោរពទៅតាមវិធានវិន័យ និងសីលធម៌ជានិស្សិត
- ត្រូវស្លៀកពាក់ឯកសណ្ឋានទៅតាមការកំណត់របស់សាកលវិទ្យាល័យ
- មិនត្រូវបរិភោគអាហារ និងភេសជ្ជៈក្នុងបន្ទប់សិក្សា
- មិនត្រូវជក់បារី និងគ្រឿងស្រវឹងនៅក្នុងបរិវេណសាកលវិទ្យាល័យ។

**ប្រការ ៤០**.- និស្សិតត្រូវសម្តែងនូវការគោរពចំពោះអ្នកដទៃរួមមាន៖
- មិនត្រូវប្រើភាសាការស្តែងចេញសកម្មភាព រូបភាពបញ្ជូនសារ ឬតាមរូបភាពផ្សេងៗណាដែលប៉ះពាល់ដល់សីលធម៌ និងសេចក្តីថ្លៃថ្នូរ
- គោរពដល់សាស្ត្រាចារ្យក្នុងលក្ខណៈវិជ្ជាជីវៈ
- ត្រូវគោរពនិងយោគយល់ចំពោះមិត្តរួមថ្នាក់ទាំងក្នុង និងក្រៅបរិវេណសាកលវិទ្យាល័យ
- មិនត្រូវបង្ក ឬធ្វើអ្វីដែលអាចនឹងបង្កនូវអសន្តិសុខ និងគ្រោះថ្នាក់ដល់អ្នកដទៃ
- គោរពចំពោះខ្លួនឯង និងអ្នកមានសមត្ថកិច្ចក្នុងសាកលវិទ្យាល័យ។

**ប្រការ ៤១**.- និស្សិតត្រូវគោរពតាមបម្រាម និងមិនត្រូវបំពានលើទ្រព្យសម្បត្តិរបស់សាកលវិទ្យាល័យរួមមាន ៖
- មិនត្រូវបង្ក ឬធ្វើអ្វីដែលអាចនឹងប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់សាកលវិទ្យាល័យ
- ចូលរួមរក្សាអនាម័យនិងភាពស្អាត ។

## ជំពូកទី៧
## សិល្បៈ វប្បធម៌ សហគមន៍ កីឡា សុខភាព ធានារ៉ាប់រង និងការចូលរួមក្នុងកម្មវិធីផ្សេងៗ

**ប្រការ៤២.- អំពីសិល្បៈ វប្បធម៌ និងសហគមន៍**

និស្សិតអាចចូលរួមក្នុងសកម្មភាពសិល្បៈ វប្បធម៌ សហគមន៍ ដែលរៀបចំឡើងដោយសាកលវិទ្យាល័យ ឬដៃគូ ដើម្បីចូលរួមចំណែកលើកស្ទួយ និងអភិរក្សសិល្បៈ វប្បធម៌ ប្រពៃណីជាតិ និងអត្តសញ្ញាណជាតិ។

**ប្រការ៤៣.- អំពីកីឡា**

និស្សិតអាចចូលរួមក្នុងសកម្មភាពកីឡា ដែលរៀបចំដោយសាកលវិទ្យាល័យ និងអាចចូលរួមក្នុងការប្រកួតប្រជែងជ្រើសរើសជើងឯកប្រចាំសាកលវិទ្យាល័យ និងថ្នាក់ជាតិ។

**ប្រការ៤៤.- សេវាសុខភាព និងធានារ៉ាប់រង**

និស្សិតដែលមានជំងឺ អាចមកពិគ្រោះ និងព្យាបាលជំងឺនៅមន្ទីរពេហុព្យាបាលនិងសម្ភពអង្គរធំដែលជាដៃគូរបស់សាកលវិទ្យាល័យ ដោយទទួលបានការបញ្ចុះតម្លៃ ០៥ភាគរយ។ ដោយឡែក ចំពោះការពិគ្រោះ និងព្យាបាលជំងឺមាត់ធ្មេញ ត្រូវទៅមន្ទីរពេទ្យហង្សនាគដោយទទួលបានការបញ្ចុះតម្លៃ ០៥ភាគរយ។

និស្សិតដែលមានជំងឺឆ្លង ឬមានជំងឺធ្ងន់ធ្ងរជាប្រចាំ ត្រូវអនុញ្ញាតច្បាប់ឈប់សម្រាកតាមវេជ្ជបញ្ជា ឬការណែនាំរបស់គ្រូពេទ្យ។

ករណីនិស្សិតមានបញ្ហា**គ្រោះថ្នាក់ផ្សេងៗ** ( លើកលែងបញ្ហាសុខភាព ) ក្នុងរយៈពេល ២៤ម៉ោង ៧ថ្ងៃក្នុងមួយសប្តាហ៍ សូមទំនាក់ទំនងមកលោក **ផេង ចន្ទា** ទូរសព្ទលេខ៖ ០១១/០៨៧ ៧៦ ២០០៧ ដើម្បីទទួលបានសេវា ធានារ៉ាប់រងគ្រោះថ្នាក់ ដែលឧបត្ថម្ភដោយផ្ទាល់ពីឯកឧត្តមបណ្ឌិត **ឌួង លាង** ប្រធានក្រុមប្រឹក្សាភិបាល សាកលវិទ្យាល័យ អាស៊ីអឺរ៉ុប។

**ប្រការ៤៥.- ការចូលរួមកម្មវិធីផ្សេងៗ**

និស្សិតត្រូវចូលរួមក្នុងកម្មវិធីផ្សេងៗ ដែលរៀបចំដោយសាកលវិទ្យាល័យដូចជា ៖

- ការប្រគល់សញ្ញាបត្រ/វិញ្ញាបនបត្រ
- ការតាំងពិព័រណ៍ប្រចាំឆ្នាំ
- ការចុះទស្សនកិច្ចសិក្សា/កម្មសិក្សា
- សិក្ខាសាលា បាឋកថា សន្និសីទ
- ការការពារនិក្ខេបបទ/សារណា
- សកម្មភាពអតីតនិស្សិត ( Alumni Activities )
- ការប្រជុំផ្សព្វផ្សាយផែនការផ្សេងៗ
- ការងារសហគមន៍/សប្បុរសធម៌
- ការចែករង្វាន់លើកទឹកចិត្តដល់និស្សិតឆ្នើម។ល។

រាល់កម្មវិធីនានា ដែលរៀបចំដោយនិស្សិតនៅក្នុងសាកលវិទ្យាល័យត្រូវបានស្វាគមន៍ ប៉ុន្តែត្រូវមានការអនុញ្ញាតជាមុនពីគណៈគ្រប់គ្រងសាកលវិទ្យាល័យ។

## ជំពូកទី៨

## វិធានការរដ្ឋបាល និងការលើកទឹកចិត្ត

**ប្រការ៤៦.- វិធានការរដ្ឋបាល**

និស្សិតដែលប្រព្រឹត្តខុសនឹងវិន័យរបស់សាកលវិទ្យាល័យនឹងត្រូវទទួលពិន័យណាមួយ ដូចខាងក្រោម ៖

- ការណែនាំដោយផ្ទាល់មាត់
- ការព្រមានជាលាយលក្ខណ៍អក្សរ

- បិទប្រកាសផ្សាយជាសាធារណៈនៅក្នុងបរិវេណសាកលវិទ្យាល័យ
- ឱ្យបង់សំណងជាប្រាក់ទៅតាមទំហំនៃការខូចខាតសម្ភារៈរបស់សាកលវិទ្យាល័យ
- ចារឹកក្នុងឯកសារវាយតម្លៃរបស់និស្សិតនៃសាកលវិទ្យាល័យ
- ព្យួរការសិក្សា
- បញ្ឈប់ការសិក្សាជាស្ថាពរពីសាកលវិទ្យាល័យដោយគ្មានលក្ខខណ្ឌ។

**ប្រការ៤៧.- ការលើកទឹកចិត្ត**

និស្សិតដែលគោរពវិន័យ និងសីលធម៌ល្អ និងជានិស្សិតឆ្នើមរបស់សាកលវិទ្យាល័យ នឹងត្រូវទទួលនូវការលើកទឹកចិត្តណាមួយដូចខាងក្រោម ៖

- តាំងរូបថតនៅលើតារាងកិត្តិយស និង/ឬ ផ្សាយតាមព្រឹត្តិបត្ររបស់សាកលវិទ្យាល័យ
- ជូនលិខិត ឬប័ណ្ណសរសើរ
- ជូនរង្វាន់
- ផ្តល់អាហារូបករណ៍
- ចារឹកក្នុងឯកសារវាយតម្លៃរបស់និស្សិត។

**ប្រការ៤៨.- នីតិវិធីនៃបណ្តឹងតវ៉ា**

រាល់បណ្តឹងតវ៉ាលើសេវាកម្មអ្វីមួយដែលនិស្សិតយល់ឃើញថា មិនត្រឹមត្រូវ ឬមិនអាចទទួលយកបាន និស្សិតត្រូវដាក់ពាក្យស្នើសុំដំណោះស្រាយឬដាក់ពាក្យបណ្តឹងមកផ្នែក ឬការិយាល័យ ឬដេប៉ាតឺម៉ង់ ឬមហាវិទ្យាល័យដែលពាក់ព័ន្ធតាមឋានានុក្រមដែលបានកំណត់ ជៀសវាងរំលងឋានានុក្រម និងផ្សព្វផ្សាយតាមបណ្តាញសង្គម។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

**ប្រការ៤៩.- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីបទបញ្ជាផ្ទៃក្នុងនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥០.- អង្គភាពនិងសុពលភាពអនុវត្តន៍**

គណៈគ្រប់គ្រង បុគ្គលិកជាន់ខ្ពស់ បុគ្គលិករដ្ឋបាល សាស្ត្រាចារ្យ និងផ្នែកពាក់ព័ន្ធត្រូវអនុវត្តន៍បទបញ្ជាផ្ទៃក្នុងសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្ររង ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងបរិញ្ញាបត្រ នៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប នេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១៦

**សាកលវិទ្យាធិការ**

បណ្ឌិត **ជា សុភាព**

**ចម្លងជូន**

-ក្រសួងអប់រំ យុវជន និងកីឡា
"ដើម្បីជូនជ្រាប"
-ដូចប្រការ៥០ "ដើម្បីអនុវត្តន៍"
-កាលប្បវត្តិ-ឯកសារ